# គោលការណ៍ណែនាំបរិស្ថាន

# ស្តីពី

# ការគ្រប់គ្រងសំណល់រឹងនៅព្រះរាជាណាចក្រកម្ពុជា

រៀបចំដោយ : ក្រសួងបរិស្ថាន និងអង្គការកែច្នៃសំរាមនិងការសិក្សានៅកម្ពុជា (COMPED)

ក្រោមគំរោង : កម្មវិធីពង្រឹងសមត្ថភាព និងគោលការណ៍គ្រប់គ្រងសំណល់រឹងនៅព្រះរាជាណាចក្រកម្ពុជា

ឧបត្ថម្ភថវិកាដោយ : សហគមន៍អឺរ៉ុប EU (AsiaProEco Programme)

ASIA PRO ECO

EUROPEAID
CO-OPERATION OFFICE

កុម្ភៈ ២០០៦

# គោលការណ៍ណែនាំបរិស្ថាន

## ស្តីពី

# ការគ្រប់គ្រងសំណល់រឹងនៅព្រះរាជាណាចក្រកម្ពុជា


រៀបចំដោយ : ក្រសួងបរិស្ថាន និងអង្គការកែច្នៃសំរាមនិងការសិក្សានៅកម្ពុជា (COMPED)

ក្រោមគំរោង : កម្មវិធីពង្រឹងសមត្ថភាព និងគោលការណ៍គ្រប់គ្រងសំណល់រឹងនៅព្រះរាជាណាចក្រកម្ពុជា

ឧបត្ថម្ភថវិកាដោយ : សហគមន៍អឺរ៉ុប EU (AsiaProEco Programme)

កុម្ភៈ ២០០៦

# សេចក្តីយល់ឃើញរបស់ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត

បច្ចុប្បន្ន ដោយមានការអភិវឌ្ឍន៍សេដ្ឋកិច្ច ស្របជាមួយនឹងកំណើនប្រជាពលរដ្ឋ និងតំរូវការប្រើប្រាស់សំភារៈក្នុងជីវភាពរស់នៅប្រចាំថ្ងៃជាការចាំបាច់ ជាហេតុបង្កឱ្យមានបញ្ហាបរិស្ថាន ដោយសារការបោះបង់ចោលសំណល់រឹងរបស់ប្រជាពលរដ្ឋនៅតាមបណ្តាខេត្ត ក្រុង បានជះឥទ្ធិពលលើសុខភាពសាធារណៈ និងបរិស្ថាន ។ ដោយពិនិត្យឃើញនូវបញ្ហាកើតមាននេះ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ និងចាត់វិធានការមួយចំនួនដូចជា : ការរៀបចំលិខិតបទដ្ឋានច្បាប់ ដើម្បីធានាការគ្រប់គ្រងសំណល់រឹងឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាពបរិស្ថាន ការពង្រឹងសមត្ថភាពមន្ត្រីជំនាញ ការអប់រំប្រជាពលរដ្ឋឱ្យយល់ដឹងផលប៉ះពាល់ដែលនឹងអាចកើតមានដល់ខ្លួន និងការបោះបង់ចោលសំណល់ឱ្យមានសណ្តាប់ធ្នាប់ និងប្រកបដោយអនាម័យបរិស្ថាន ក៏ដូចជាការជំរុញដល់ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុនឯកជនអនុវត្តតាមលិខិតបទដ្ឋានច្បាប់ដែលមានហើយ ។

ឯកសារគោលការណ៍ណែនាំបរិស្ថាននេះ ជាកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងបរិស្ថាន និងអង្គការ COMPED ជាដៃគូរបស់ក្រសួង បានរៀបចំឱ្យមានជាគោលការណ៍ណែនាំបរិស្ថាន ស្តីពី **ការគ្រប់គ្រងសំណល់រឹងនៅព្រះរាជាណាចក្រកម្ពុជា** ដែលឯកសារនេះបានណែនាំលំអិតបន្ថែមសំរាប់ជំរុញការអនុវត្តលិខិតបទដ្ឋានច្បាប់ដែលមានស្រាប់ ហើយវាមានសារប្រយោជន៍ និងជាមូលដ្ឋានជួយដល់ស្ថាប័នពាក់ព័ន្ធ ជាពិសេសអាជ្ញាធរដែនដីខេត្ត ក្រុង និងផ្នែកឯកជនក្នុងការកែលំអការគ្រប់គ្រងសំណល់រឹងដែលកំពុងជួបបញ្ហាឱ្យមានភាពប្រសើរឡើងក្នុងពេលអនាគត ។

ឯកសារគោលការណ៍ណែនាំបរិស្ថាននេះ បានបង្ហាញពីលក្ខណៈបច្ចេកទេសលើការគ្រប់គ្រងសំណល់រឹងដូចជា:

- ការរៀបចំផែនការគ្រប់គ្រងសំណល់សំរាប់អាជ្ញាធរខេត្ត ក្រុង និងក្រុមហ៊ុនឯកជនក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង ។
- ការរៀបចំទីលាន ដំណើរការទីលាន និងការថែទាំទីលានក្នុងពេលបិទ ។
- វិធីសាស្ត្រ និងល័ក្ខខ័ណ្ឌក្នុងការធ្វើជីកំប៉ុស្តិ៍ ។
- ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រដែលជាប្រភេទប្រកបដោយគ្រោះថ្នាក់ ។
- ការបង្ហាញនូវលក្ខណៈ និងវិធីដែលត្រូវអនុវត្តក្នុងការអប់រំបរិស្ថានដល់មហាជនទូទៅ ។

ដោយពិនិត្យឃើញនូវសារប្រយោជន៍នៃគោលការណ៍ណែនាំបរិស្ថាននេះ ក្រសួងបរិស្ថាន សូមគាំទ្រទាំងស្រុងដល់ខ្លឹមសារឯកសារនេះ ហើយសង្ឃឹមថា ឯកសារនេះ នឹងជួយដល់ស្ថាប័នពាក់ពន្ធ័ និងផ្នែកឯកជនដ៏ទៃទៀតដែលមានមានភាពកិច្ចក្នុងនាមជាម្ចាស់សំណល់នូវវិធីសាស្ត្រគ្រប់គ្រងប្រកបដោយសុវត្ថិភាពបរិស្ថាន ។

រាជធានីភ្នំពេញថ្ងៃទី ០៩ ..ខែ [illegible] ឆ្នាំ២០០៦

**តេជោសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

ម៉ុក_ម៉ារ៉េត
បណ្ឌិត.ជីវវិទ្យា

# អារម្ភកថា

គោលការណ៍ណែនាំបរិស្ថាន ស្តីពី ការគ្រប់គ្រងសំណល់រឹងនៅព្រះរាជាណាចក្រកម្ពុជា រៀបចំឡើងតាមរយៈគំរោងកម្មវិធីពង្រឹងសមត្ថភាព និងគោលការណ៍គ្រប់គ្រងសំណល់រឹងនៅព្រះរាជាណាចក្រកម្ពុជា (Capacity Building and Policy Reinforcement in Cambodia in the Field of Waste Management) ដោយមានការឧបត្ថម្ភថវិកាពីសហគមន៍អឺរ៉ុប EU ក្រោមគំរោង AsiaProEco Programme។

បំណងនៃគំរោងគឺចូលរួមជាមួយនឹងក្រសួងបរិស្ថានក្នុងការរៀបចំ និងអនុវត្តន៍គោលការណ៍គ្រប់គ្រងបរិស្ថាន និងពង្រឹងសមត្ថភាពយល់ដឹងបរិស្ថានដល់សាធារណៈជន។

ដើម្បីសំរេចនូវគោលបំណងខាងលើ គំរោងបានរៀបចំនូវកម្មវិធីអនុវត្តន៍មួយចំនួនដូចជា បើកវគ្គបណ្តុះបណ្តាល ស្តីពី ការគ្រប់គ្រងសំណល់រឹង និងសេចក្តីព្រាងគោលការណ៍ណែនាំបរិស្ថាន ស្តីពី ការគ្រប់គ្រងសំណល់រឹង ដែលមានអង្គការ COMPED ជាអ្នកសំរបសំរួល និងជំនាញការអន្តរជាតិជាអ្នកផ្តល់ប្រឹក្សាបច្ចេកទេស និងជានិច្ចជាកាល សិក្ខាកាមតែងតែទទួលបាននូវការផ្តល់ប្រឹក្សាពីក្រសួងបរិស្ថាន។

ការរៀបចំគោលការណ៍ណែនាំខាងលើ ធ្វើឡើងដោយយោងទៅតាមបញ្ញត្តិច្បាប់ដែលមាន។

ក្នុងគោលការណ៍ណែនាំបរិស្ថាន មានការផ្តល់អនុសាសន៍បច្ចេកទេសមួយចំនួន បានចែងនៅក្នុងឧបសម្ព័ន្ធ ដែលទាមទារអោយមានការកែសំរួល (update) ជានិច្ច យោងតាមការអនុវត្តន៍ជាក់ស្តែង។

យើងខ្ញុំសង្ឃឹមថាគោលការណ៍ណែនាំនេះ ជាជំនួយមួយផ្នែកក្នុងការអនុវត្តន៍នូវបញ្ញត្តិច្បាប់ប្រកបដោយ សុក្រឹត និងប្រសិទ្ធភាព។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថានដែលជានិច្ចជាកាលតែងតែគាំទ្រនូវគំរោងកម្មវិធីបរិស្ថាន។

**ភ្នំពេញ ថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ២០០៦**

**នាយក អង្គការកែច្នៃសំរាមនិងការសិក្សានៅកម្ពុជា**

Heng

**ជោ គីមហេង**

# រៀបចំដោយ

## ក្រុមទី ១. គោលការណ៍ណែនាំ ស្តីពី ការរៀបចំផែនការគ្រប់គ្រងសំណល់រឹង

| | |
|---|---|
| លោក ជិន សុធន់ | ក្រសួងបរិស្ថាន នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន |
| លោក សុខ វុទ្ធា | ក្រសួងបរិស្ថាន នាយកដ្ឋានអប់រំព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន |
| លោក ម៉ៃ វណ្ណៈ | មន្ទីរបរិស្ថានរាជធានីភ្នំពេញ |
| លោក ឃួន តារា | មន្ទីរបរិស្ថានរាជធានីភ្នំពេញ ទទួលបន្ទុកខណ្ឌទួលគោក |
| លោក លឹម កែន | មន្ទីរបរិស្ថានរាជធានីភ្នំពេញ ទទួលបន្ទុកខណ្ឌចំការមន |
| លោក ជេង វិរៈ | មន្ទីរបរិស្ថានខេត្តកណ្ដាល |

## ក្រុមទី ២. គោលការណ៍ណែនាំ ស្តីពី ការសាងសង់និងគ្រប់គ្រងទីលាន

| | |
|---|---|
| លោក ថោរ សុភាព | មន្ទីរបរិស្ថានខេត្តកណ្ដាល |
| លោក ហ៊ាង ញ៉ | មន្ទីរបរិស្ថានរាជធានីភ្នំពេញ |
| លោក ឃុយ គុយនី | មន្ទីរបរិស្ថានរាជធានីភ្នំពេញ |
| លោក អ៊ូ សុភ័ន្ត | ក្រសួងបរិស្ថាន នាយកដ្ឋានអង្កេត ពិនិត្យ ការវាយតំលៃ ហេតុប៉ះពាល់បរិស្ថាន |
| លោក សួន ពន្លក | ក្រសួងបរិស្ថាន នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន |
| លោក អ៊ុំ សោភ័ណ្ឌ | រដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ |

## ក្រុមទី ៣. គោលការណ៍ណែនាំ ស្តីពី ការធ្វើជីកំប៉ុស្ត៍

| | |
|---|---|
| លោក ពុំ អឿ | មន្ទីរបរិស្ថានរាជធានីភ្នំពេញ ទទួលបន្ទុកខណ្ឌមានជ័យ |
| លោក ង៉ែត បុល | ក្រសួងបរិស្ថាន នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន |
| លោក ប៊ូ សំខាន់ | អង្គការកែច្នៃ និងអនាម័យសហគមន៍ |
| លោក ទិត្យ សុផាណារ៉ា | មន្ទីរបរិស្ថានខេត្តកណ្ដាល |
| លោក ពេជ្រ អ៊ី | មន្ទីរបរិស្ថានរាជធានីភ្នំពេញ ទទួលបន្ទុកខណ្ឌដង្កោរ |
| លោក អៀម ស៊ីថា | មន្ទីរបរិស្ថានរាជធានីភ្នំពេញ ទទួលបន្ទុកខណ្ឌ៧មករា |

**ក្រុមទី ៤.គោលការណ៍ណែនាំ ស្តីពី ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ**

| | |
|---|---|
| លោក សារុន សំបូរ | ក្រសួងបរិស្ថាន នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន |
| លោក សោម សីហារត្ន័ | ក្រសួងសុខាភិបាល |
| លោក សរ សុង | មន្ទីរបរិស្ថានរាជធានីភ្នំពេញ |
| លោក លី ហួត | ក្រសួងបរិស្ថាន នាយកដ្ឋានផែនការ និងកិច្ចការច្បាប់ |
| លោក អ៊ួង ប៊ុនណាល់ | មន្ទីរបរិស្ថានរាជធានីភ្នំពេញ |
| លោក ជឹម ឡា | មន្ទីរបរិស្ថានខេត្តកណ្តាល |

**ក្រុមទី ៥.គោលការណ៍ណែនាំ ស្តីពី ការអប់រំបរិស្ថាន**

| | |
|---|---|
| លោក យិន ប៊ុនណាង | ក្រសួងបរិស្ថាន នាយកដ្ឋានអប់រំព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន |
| លោក អ៊ូ វិទូ | ក្រសួងបរិស្ថាន នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន |
| លោក លី ឡុង | មន្ទីរបរិស្ថានរាជធានីភ្នំពេញ ទទួលបន្ទុកខណ្ឌឫស្សីកែវ |
| លោក ហ៊ុយ ផលវុឌ្ឍី | មន្ទីរបរិស្ថានខេត្តកណ្តាល |
| លោក កុក សុធា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

## ទីប្រឹក្សាបច្ចេកទេស

- Bauhaus Universität Weimar (European Project Applicant)
- Scuola Agraria del Parco di de Monza (European project partner)
- KNOTEN WEIMAR GmbH, Germany
- Thüringer Ministerium für Landwirtschaft, Naturschutz und Umwelt, Germany
- Bioverwertung &Recycling GmbH Erfurt, Germany

# មាតិកា

ទំព័រ

**I. សេចក្តីផ្តើម**

១. គោលបំណង និងទិសដៅនៃគោលការណ៍ណែនាំ ...................... ១

២. បញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹង........................ ១

២.១ ច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ..... ១

២.២ អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពី ការគ្រប់គ្រងសំណល់រឹង...... ១

២.៣ ប្រកាសអន្តរក្រសួងមហាផ្ទៃ-បរិស្ថាន លេខ ៨០ ប្រក.មផ_បស្ត ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹង នៅក្នុងខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា........................................ ២

៣. វិសាលភាពនៃគោលការណ៍ណែនាំ........................................ ២

**II. និយមន័យ**.................................................................. ៣

**III. គោលការណ៍ណែនាំ ស្តីពី ការរៀបចំផែនការគ្រប់គ្រងសំណល់រឹង**

១. គោលបំណង........................................................... ៧

២. ការរៀបចំផែនការគ្រប់គ្រងសំណល់រឹង................................ ៧

៣. ទិន្នន័យនិងទំរង់បែបបទរៀបចំផែនការគ្រប់គ្រងសំណល់រឹង................ ៨

៣.១ ទិន្នន័យនៅក្នុងផែនការគ្រប់គ្រងសំណល់រឹង........................ ៨

៣.២ ប្រភេទ បរិមាណ និងប្រភពសំណល់........................... ៨

៣.៣ លំហូរសំណល់................................................ ៩

៣.៤ វិធានការ.......................................................... ៩

៣.៥ បែបបទនៃការសរសេរគំរោងផែនការ............................. ១០

៣.៦ ការប្រៀបធៀបផែនការចូលគ្នា................................... ១០

៣.៧ ព័ត៌មានសំខាន់ៗដែលត្រូវការសំរាប់រៀបចំផែនការ គ្រប់គ្រងសំណល់រឹង.................................................. ១០

IV. គោលការណ៍ណែនាំ ស្តីពី ការសាងសង់ និងការគ្រប់គ្រងទីលាន

១. គោលបំណង......................................................១១
២. ប្រភេទទីលាន......................................................១១
៣. តម្រូវការទីលាន......................................................១២
    ៣.១ លក្ខខណ្ឌទូទៅនៃទីលាន......................................................១២
    ៣.២ តម្រូវការចាំបាច់សំរាប់ទីលានបទដ្ឋានសាមញ្ញ......................................................១៣
    ៣.៣ តម្រូវការចាំបាច់សំរាប់ទីលានអនាម័យ......................................................១៤
៤. លក្ខខណ្ឌនានាដើម្បីសុំការអនុញ្ញាត......................................................១៣
៥. សំណល់ដែលមិនអនុញ្ញាតឱ្យចាក់ចោលលើទីលានបទដ្ឋានសាមញ្ញ
    និងទីលានអនាម័យ......................................................១៤
៦. លក្ខខណ្ឌក្នុងការជ្រើសរើសទីតាំងសាងសង់ទីលាន......................................................១៥
៧. ប្រព័ន្ធប្រមូលឧស្ម័ន និងទឹកសំអុយទីលាន......................................................១៦
៨. ដំណើរការទីលាន......................................................១៦
    ៨.១ រចនាសម្ព័ន្ធដឹកនាំ......................................................១៦
    ៨.២ ការគ្រប់គ្រងសំណល់នាំចូលទីលានទាំងបីប្រភេទ......................................................១៦
    ៨.៣ បុគ្គលិកធ្វើការនៅទីលានទាំងបីប្រភេទ......................................................១៧
    ៨.៤ ការត្រួតពិនិត្យគុណភាពទឹកក្រោមដី......................................................១៨
៩. ការត្រួតពិនិត្យ និងការអង្កេត......................................................១៨
    ៩.១ ពេលដំណើរការទីលាន......................................................១៨
    ៩.២ ក្រោយពេលបិទទីលាន......................................................១៩
១០. ការគ្របទីលានបញ្ចប់ និងការគ្រប់គ្រងបន្ត......................................................១៩
    ១០.១ ការគ្របចុងក្រោយ......................................................១៩
    ១០.២ ការដាំរុក្ខជាតិឡើងវិញ......................................................១៩

V. គោលការណ៍ណែនាំ ស្តីពី ការធ្វើជីកំប៉ុស្ត៍

១. គោលបំណង......................................................២០
២. វត្ថុធាតុដើមដែលអនុញ្ញាតឱ្យយកធ្វើជីកំប៉ុស្តិ៍......................................................២០

២.១ លក្ខខណ្ឌទូទៅ................................................................. ២០

២.២ សំណល់ជីវៈ.................................................................. ២០

២.៣ ប្រភេទសំណល់ផ្សេងៗទៀត.................................................. ២១

២.៤ សំណល់ភក់.................................................................. ២១

៣. សារធាតុដែលមិនអនុញ្ញាតអោយយកធ្វើជាវត្ថុធាតុដើមធ្វើជីកំប៉ុស្តិ៍.......... ២១

៤. ផលិតផលជីកំប៉ុស្តិ៍................................................................ ២២

៤.១ លក្ខខណ្ឌជីកំប៉ុស្តិ៍.......................................................... ២២

៤.២ លក្ខខណ្ឌផលិតផលជីកំប៉ុស្តិ៍............................................... ២២

៥. តម្រូវការសំរាប់ដំណើរការធ្វើជីកំប៉ុស្តិ៍............................................. ២៤

៦. ទីលានធ្វើជីកំប៉ុស្តិ៍................................................................. ២៥

៦.១ ទីតាំងទីលានធ្វើជីកំប៉ុស្តិ៍.................................................... ២៥

៦.២ ការសាងសង់ទីលានធ្វើជីកំប៉ុស្តិ៍.............................................. ២៦

៧. ការអនុញ្ញាតសំរាប់ទីលានធ្វើជីកំប៉ុស្តិ៍............................................... ២៧

## VI. គោលការណ៍ណែនាំ ស្តីពី ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ

១. គោលបំណង.......................................................................... ២៨

២. ប្រភពសំណល់វេជ្ជសាស្ត្រ.......................................................... ២៨

៣. ប្រភេទសំណល់វេជ្ជសស្ត្រ.......................................................... ២៨

៤. ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ.................................................. ២៩

៤.១ ការញែកសំណល់នៅប្រភព................................................... ២៩

៤.២ ការទុកដាក់បណ្តោះអាសន្នប្រកបដោយសុវត្ថិភាព......................... ៣០

៥. ការត្រួតពិនិត្យជាប្រចាំសំណល់វេជ្ជសាស្ត្រ........................................ ៣០

៥.១ ភារកិច្ចម្ចាស់សំណល់ប្រភេទ ខ និង គ.......................................... ៣០

៥.២ ភារកិច្ចក្រុមហ៊ុនដឹកជញ្ជូន................................................... ៣១

៥.៣ ភារកិច្ចអ្នកទទួល............................................................... ៣១

៦. ការធ្វើប្រព្រឹត្តកម្មសំណល់វេជ្ជសាស្ត្រប្រភេទ ខ និង គ............................ ៣២

៧. ការបោះបង់ចុងក្រោយនៃសំណល់វេជ្ជសាស្ត្រ...................................... ៣២

៨. ការពង្រឹង និងបង្កើនសមត្ថភាព........................................ ៣៣

VII. គោលការណ៍ណែនាំ ស្តីពី ការអប់រំបរិស្ថាន

១. គោលបំណង........................................ ៣៤

២. គោលការណ៍អប់រំបរិស្ថាន........................................ ៣៤

៣. មុខសញ្ញា........................................ ៣៥

៤. ផែនការអប់រំបរិស្ថាន........................................ ៣៥

៤.១ ខ្លឹមសារអប់រំបរិស្ថាន........................................ ៣៦

៤.២ ផែនការអប់រំបរិស្ថាន........................................ ៣៧

៤.៣ សកម្មភាពអប់រំបរិស្ថាន........................................ ៣៧

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១ តារាងបែងចែកប្រភេទសំណល់រឹង........................................ ៣៨

ឧបសម្ព័ន្ធ ២ មធ្យោបាយចាក់ចោល........................................ ៤៥

ឧបសម្ព័ន្ធ ៣ មធ្យោបាយប្រព្រឹត្តកម្ម........................................ ៤៥

ឧបសម្ព័ន្ធ ៤ ទំរង់បែបបទផែនការគ្រប់គ្រងសំណល់រឹង........................................ ៤៦

ឧបសម្ព័ន្ធ ៥ ប្រភេទសំណល់ដែលត្រូវចាក់ចោលនៅទីលានប្រភេទផ្សេងៗគ្នា.... ៤៨

ឧបសម្ព័ន្ធ ៦ កំណត់សំគាល់បច្ចេកទេស........................................ ៥៧

ឧបសម្ព័ន្ធ ៧ កម្រិតកំណត់លោហៈធ្ងន់សំរាប់សំណល់ភក់ដែលយកទៅធ្វើជីកំប៉ុស្តិ៍.. ៨៧

ឧបសម្ព័ន្ធ ៨ លោហៈធ្ងន់ដែលអនុញ្ញាតឱ្យមាននៅក្នុងជីកំប៉ុស្តិ៍........................................ ៨៧

ឧបសម្ព័ន្ធ ៩ តំរូវការបច្ចេកទេសសំរាប់មធ្យោបាយប្រព្រឹត្តកម្មជីវៈ........................................ ៨៨

ឧបសម្ព័ន្ធ ១០ ប្រភេទសំណល់វេជ្ជសាស្ត្រ........................................ ៩៤

ឧបសម្ព័ន្ធ ១១ បែបបទការដឹកជញ្ជូន និងការចាក់ចោលសំណល់វេជ្ជសាស្ត្រ.... ៩៧

# I. សេចក្តីផ្តើម

## ១. គោលបំណង និងទិសដៅនៃគោលការណ៍ណែនាំ

គោលបំណងនៃគោលការណ៍ណែនាំបរិស្ថាន ស្តីពី ការគ្រប់គ្រងសំណល់រឹងនៅព្រះរាជាណាចក្រកម្ពុជា គឺធានានូវកិច្ចការពារសុខភាពសាធារណៈ បរិស្ថាន និងអភិរក្សជីវៈចំរុះ ជៀសផុតពីការបំពុលបង្កដោយបញ្ហាសំណល់រឹង។

ដើម្បីសំរេចឱ្យបាននូវគោលបំណងខាងលើ គោលការណ៍ណែនាំមានទិសដៅក្នុងការអនុវត្តន៍ដូចខាងក្រោមនេះ÷

- ជំរុញការអនុវត្តគោលការណ៍កាត់បន្ថយការបង្កើតសំណល់ កាត់បន្ថយបរិមាណសំណល់ ការប្រើប្រាស់ឡើងវិញ ការកែច្នៃ និងការចាក់ចោលសំណល់ឱ្យបានត្រឹមត្រូវ និងដោយសុវត្ថិភាព។
- ជំរុញការអប់រំប្រជាពលរដ្ឋ និងសារធារណៈជនគ្រប់ស្រទាប់ជាន់ថ្នាក់ ឱ្យបានយល់និងស្គាល់នូវអត្ថន័យ ព្រមទាំងសារៈសំខាន់នៃកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិនាពេលបច្ចុប្បន្ន និងទៅអនាគត ព្រមទាំងការយល់ដឹងអំពីការអភិវឌ្ឍន៍ដោយចេរភាពបរិស្ថាន។
- ជំរុញការរៀបចំផែនការគ្រប់គ្រងសំណល់រឹងឱ្យបានសមស្រប នាំមកនូវការអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយចេរភាព ការពារឱ្យបាននូវទ្រព្យសម្បត្តិធម្មជាតិ និងតាមរយៈសកម្មភាពគ្រប់គ្រងសំណល់រឹង បង្កើតឱ្យមានការងារធ្វើ។

## ២. បញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹង

### ២.១ ច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

**មាត្រា ១៣:** ការទប់ស្កាត់ កាត់បន្ថយ និងការត្រួតពិនិត្យការបំពុលអាកាស ទឹក ដី ការរំខានដោយសម្លេង និងរំញ័រ ព្រមទាំងសំណល់សារធាតុពុល និងសារធាតុប្រកបដោយគ្រោះថ្នាក់ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន។

### ២.២ អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពី ការគ្រប់គ្រងសំណល់រឹង

**មាត្រា ១:** អនុក្រឹត្យនេះមានគោលដៅ កំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវ

ការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ។

**មាត្រា ៨:** ក្រសួងបរិស្ថានត្រូវរៀបចំប្រកាស ស្តីពី គោលការណ៍ណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាម តាមបណ្តាខេត្ត ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាម ប្រកបដោយសុវត្ថិភាព។

អាជ្ញាធរខេត្ត-ក្រុងត្រូវរៀបចំផែនការគ្រប់គ្រងសំរាមនៅក្នុងខេត្ត-ក្រុងរបស់ខ្លួន សំរាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។

**មាត្រា ១១:** ក្រសួងបរិស្ថានត្រូវរៀបចំប្រកាស ស្តីពី គោលការណ៍ណែនាំ លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយសុវត្ថិភាព។

## ២.៣ ប្រកាសអន្តរក្រសួងមហាផ្ទៃ-បរិស្ថាន ៨០ ប្រក.មផ-បស្ថ ស្តីពី ការគ្រប់គ្រងសំរាមសំណល់រឹង នៅខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១:** ប្រកាសនេះមានគោលបំណង ជំរុញកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវវិធានការគ្រប់គ្រងសំរាម សំណល់រឹង នៅក្នុងខេត្ត ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន សំដៅធានាបាននូវកិច្ចការពារសុខភាពសាធារណៈ សោភ័ណភាព គុណភាពបរិស្ថាន និងជីវចំរុះ។

**មាត្រា ២:** ប្រកាសនេះមានវិសាលភាពអនុវត្តទៅលើរាល់សកម្មភាពប្រមូល សំអាត ស្តុកបណ្តោះអាសន្ន ដឹកជញ្ជូន កែច្នៃ សំណល់រឹងគ្រប់ប្រភេទ នៅតាមខេត្ត ក្រុងនៃព្រះរាជាណាចក្រកម្ពុជា។

## ៣. វិសាលភាពនៃគោលការណ៍ណែនាំ

គោលការណ៍ណែនាំនេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ ធ្វើប្រព្រឹត្តកម្ម ធ្វើជីកំប៉ុស្ត៍ និងការបោះបង់ចោលចុងក្រោយ នៃសំណល់រឹងគ្រប់ប្រភេទ។

## II. និយមន័យ

ពាក្យបច្ចេកទេសដែលមានប្រើក្នុងឯកសារនេះ ត្រូវបានបកស្រាយ ឬកំណត់ន័យដូចតទៅ÷

__សំណល់រឹង__ (solid waste) គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង សំភារៈ ឬរបស់កំទេចកំទីដែលគេលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតំរូវអោយបោះបង់ចោល។

__សំណល់រឹងមិនបង្កគ្រោះថ្នាក់__ (non-hazardous solide waste) ជាសំណល់ដែលមិនបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងរុក្ខជាតិ ដូចជាសំណល់រឹងទូទៅតាមផ្ទះ ទីផ្សារ ទីសាធារណៈ ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ សួនច្បារ អាគារពាណិជ្ជកម្ម។ល។ (មើលឧបសម្ព័ន្ធ ១)

__សំណល់រឹងប្រកបដោយគ្រោះថ្នាក់__ (hazardous solide waste) គឺសំដៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កឱ្យមានជំងឺមហារីក ចម្លងជំងឺ ធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម ឬ សារធាតុគីមីផ្សេងទៀតដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬ មានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសារធារណៈ និងបរិស្ថាន។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រ ឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្ម អាជីវកម្មរ៉ែ ។ល។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការគ្រប់គ្រងសំណល់រឹង។

__សំណល់រឹងទីក្រុង__ (municipal solid waste) ដូចជាសំណល់រឹងតាមផ្ទះ សំណល់រឹងស្រដៀងសំណល់តាមផ្ទះ ដូចជាលំនៅស្ថាន អាគារសាធារណៈ រោងចក្រ សហគ្រាស ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មន្ទីរពេទ្យធ្វើដំណើរ រមណីយដ្ឋាន។ល។

__សំណល់តាមផ្ទះ__ (household waste) ជាផ្នែកមួយនៃសំណល់រឹងដែលកាតច្រើន ចេញពីផ្ទះឯកជន លំនៅស្ថាន អាគារសារធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មន្ទីរពេទ្យឯកជនតូច កន្លែងកំសាន្ត ។ល។

__សំណល់វេជ្ជសាស្ត្រ__ (medical waste) សំណល់ទាំងឡាយណាដែលកើតចេញពីមន្ទីរពេទ្យ និងសកម្មភាពវេជ្ជសាស្ត្រ។

__សំណល់ទីផ្សារ__ (market waste) សំណល់ដែលចេញពីទីផ្សារ។

**សំណល់សត្តឃាត** (slaughterhouse waste) សំណល់ដែលចេញពីកន្លែងសត្តឃាត សំរាប់សេវាកម្មសាច់ជាអាហារ។

**សំណល់កសិកម្ម** (agriculture waste) សំណល់ដែលចេញពីសកម្មភាពដាំដុះ រុក្ខជាតិ ការប្រមូលផល និងសារធាតុដែលគេឈប់ប្រើប្រាស់នៅកសិដ្ឋាន ឬស្រែចំការ។

**សំណល់សួនច្បារ** (garden waste) ស្មៅ ស្លឹកឈើ មែកឈើ។ល។

**សំណល់ឧស្សាហកម្ម** (industrial waste) សំណល់ដែលចេញពីរោងចក្រ សហគ្រាស។

**សំណល់សំណង់** (construction and demolition waste) សំណល់ដែលចេញពីសកម្មភាព សាងសង់ រុះរើសំណង់ និងសំណង់ស្ពានថ្នល់។ល។

**សំណល់មន្ទីរពិសោធន៍** (laboratory waste) ជាសំណល់នៅក្នុងមន្ទីរពិសោធន៍។

**សំណល់តាមផ្លូវ** (street swepping) សំណល់ដែលចេញពីសកម្មភាពបោសសំអាតតាមដងផ្លូវ។

**សំណល់ផ្ទះបាយ** (kitchen waste) សំណល់ម្ហូបអាហារដែលសល់ពីការដាំស្ល និងក្រោយពេលបរិភោគ ដូចជាសំណល់បន្លែ ផ្លែឈើ សាច់ ត្រី ឆ្អឹង ស្បែក រោម សំបកស៊ុត។ល។ ដោយរាប់បញ្ចូលទាំងកំទេចក្រដាស ក្រដាសកាតុងដែលប្រឡាក់ ព្រោះគេប្រើប្រាស់វាសំរាប់វេចខ្ចប់អាហារ (ឧទាហរណ៍ដូចជា ប្រអប់កាតុងជាដើម)។

**សំណល់ជីវៈ** (bio-waste) ដូចជាសំណល់ផ្ទះបាយ (កំទេចកំទីអាហារ) ដែលជាសាច់ ឬបន្លែ និងសំណល់បៃតងអាចធ្វើការបំបែកធាតុតាមជីវៈបាន។

**សំណល់ដែលអាចបំបែកធាតុក្រោមអំពើជីវៈ** (biodigradable waste) រាល់សំណល់ណាដែលអាចធ្វើការបំបែកធាតុក្រោមអំពើជីវៈ តាមបែបលក្ខខ័ណ្ឌអែរ៉ូបិក ឬអែនអែរ៉ូបិកបានដូចជាសំណល់អាហារ សំណល់បៃតង ក្រដាស និងក្រដាសកាតុងជាដើម។

**សំណល់វេចខ្ចប់** (packing waste) សំណល់នេះកើតឡើងតាមរយៈសកម្មភាពវេចខ្ចប់ដែលបោះចោលដោយអ្នកប្រើប្រាស់ចុងក្រោយ ឬអ្នកផលិត។

**សំណល់ដែលអាចកែច្នៃវិញបាន** (recyable waste) ជាសំណល់ដែលគេយកធ្វើជាវត្ថុធាតុដើមសំរាប់ផលិតផលថ្មីមួយទៀត។

**សំណល់ភក់ល្បាប់** (sewage sludge) ជាសំណល់រឹង ឬពាក់កណ្តាលរឹងដែលចេញពីការរងដោយខ្លួនឯង ឬក៏ការធ្វើប្រព្រឹត្តកម្មជីវៈនៅកន្លែងប្រព្រឹត្តកម្មសំណល់រាវទីក្រុង ឬកន្លែងធ្វើប្រព្រឹត្តកម្មសំណល់រាវឧស្សាហកម្ម ដោយរាប់បញ្ចូលទាំងសំណល់ភក់ដែលគេបានដកទឹកចេញ ឬសំងួត ឬធ្វើប្រព្រឹតកម្មតាមបែបណាមួយ។

**ទីលានចាក់សំណល់** (landfill) ជាកន្លែងមួយសំរាប់ចាក់ចោលសំណល់ណា ដែលមិនអាចយកទៅធ្វើអ្វី ឬកែច្នៃបានតទៅទៀត។

**ទឹកសំអុយទីលាន** (landfill leachate) ជាវត្ថុរាវដែលជ្រាបឆ្លងកាត់តំនរសំណល់ពុករលួយនៃទីលាន និងជ្រាបចេញពីទីលាន ព្រមទាំងទឹកសំអុយដែលនៅក្នុងទីលាន។

**ឧស្ម័នទីលាន** (landfill gas) ជាឧស្ម័នដែលកើតពីសំណល់នៅទីលានតាមរយៈការកើតឡើងដោយឯកឯង ឬការបំបែកធាតុ។

**ទឹកដែលរងការបំពុល** (contaminated water) សំដៅលើទឹកភ្លៀង ទឹកដែលលាងហូរច្រោះកាត់ទីលានសំណល់។

**ជីកំប៉ុស្តិ៍** (compost) ជាសមិទ្ធិផលចុងក្រោយនៃការធ្វើជីកំប៉ុស្តិ៍។ សមិទ្ធិផលនេះអាចប្រើជំនួសជីគីមីបាននៅក្នុងវិស័យកសិកម្ម ព្រោះវាមានសារធាតុចិញ្ចឹម ធ្វើឱ្យដីមានជីជាតិ មានរចនាសម្ព័ន្ធឡើងវិញ ធ្វើឱ្យសត្វមានប្រយោជន៍ក្នុងដីអាចរស់បាន មានលទ្ធភាពជក់ជាតិទឹកបានយូរ។

**ការធ្វើជីកំប៉ុស្តិ៍** (composting) ជាដំណើរការបំបែកធាតុតាមបែបជីវៈក្រោមលក្ខខ័ណ្ឌអែរ៉ូបិកមួយត្រឹមត្រូវ។ នៅក្នុងដំណាក់កាលនៃដំណើរការធ្វើជីកំប៉ុស្តិ៍មានការបញ្ចេញជាឧស្ម័ននិងទឹកសំអុយហើយមួយផ្នែកទៀតនៃសំណល់ពុកផុយ បំរែបំរួលពីសារធាតុជីវៈទៅជាសារធាតុមរោគ។ ដំណើរការបំរែបំរួលនេះកើតឡើងតាមរយៈសកម្មភាពពពួកមីក្រូសរីរាង្គ។ ដូចនេះការបំបែកធាតុតាមបែបអែរ៉ូបិកទាមទារឱ្យមានវត្តមានឧស្ម័នអុកស៊ីសែនជានិច្ច។

**សំណល់ឌីកេសតេត** (digestate) ជាសំណល់រឹង ឬពាក់កណ្តាលរឹងដែលកើតចេញពីការបំបែកធាតុតាមបែបអែនអែរ៉ូបិក។

**ការបំបែកធាតុតាមអែនអែរ៉ូបិក** (anaerobig degestion) ការបំបែកធាតុដោយមិនមានវត្តមានឧស្ម័នអុកស៊ីសែន។ កំដៅកើតឡើងដោយសារឧស្ម័នជីវៈ (ក្នុងនោះមានឧស្ម័នមេតាន) ហើយសមិទ្ធិផលចុងក្រោយអាចជាវត្ថុធាតុដើមយកធ្វើជីកំប៉ុស្តិ៍ ឬប្រើប្រាស់ជាជីតែម្តងសំរាប់តែដីដំណាំហូបផ្លែ។

**បច្ចេកទេសសមស្រប** (state of the art) បញ្ជាក់ថាជាបច្ចេកទេសសមស្របដែលខិតជិតទៅដល់បច្ចេកទេសនាពេលបច្ចុប្បន្ន។

**មធ្យោបាយប្រព្រឹត្តកម្មសំណល់** (waste treatment facilities) តាមបែបរូប (physical) តាមបែបកំដៅ (energy) គីមី (chemical) ឬជីវៈ (biological) ដែលរាប់បញ្ចូលទាំងការញែក ការបំរែបំរួលលក្ខណៈសម្បត្តិរបស់សំណល់។ ការប្រព្រឹត្តកម្មសំណល់ក្នុងបំណងកាត់បន្ថយមាឌវា ឬភាពគ្រោះថ្នាក់ដែលមានមកពីធម្មជាតិ។

<u>**កន្លែងចាក់សំណល់**</u> (dumping areas) ជាកន្លែងមួយនៅក្នុងបរិវេណទីលាន មានការរៀបបាតក្រោមត្រឹមត្រូវ ហើយសំណល់ដែលចាក់ចោលនៅទីនោះ ដោយមិនមានកំណត់ពេលវេលា។

<u>**កន្លែងស្តុកបណ្តោះអាសន្ន**</u> (intermediate storage area) ជាកន្លែងមួយដែលសង់មានភាពរឹងមាំ សំរាប់ទទួលសំណល់ ដើម្បីរៀបចំធ្វើប្រព្រឹត្តកម្ម ប្រមូលសំណល់សំរាប់ការគ្រប់គ្រងបន្ត ឬយកទៅចាក់ចោល។

<u>**កន្លែងស្តុក**</u> (storage area) ជាកន្លែងមួយសាងសង់ឡើង សំរាប់ស្តុកសំណល់មួយរយៈ ដើម្បីគ្រប់គ្រង និងធ្វើប្រព្រឹត្តកម្មគីមីកម្ម ទីតាំងវាស្ថិតនៅលើទីលាន។

<u>**ច្រកចូល**</u> ( entrance area) ជាកន្លែងទទួលសំណល់មកដល់ ហើយមានជញ្ជីងថ្លឹង ឬគណនាគិតជាមាឌសំណល់។ ទីតាំងរបស់វាគឺនៅកន្លែងច្រកចូលទីលាន។

<u>**កន្លែងដំណើរការការងារ**</u> (working areas) ជាកន្លែងដែលសាងសង់ឡើងសំរាប់គ្រប់គ្រងសំណល់ដែលត្រូវរៀបចំ។ កន្លែងនេះមាននៅក្បែរច្រកចូល កន្លែងស្តុកសំណល់ចុងក្រោយ ឬកន្លែងធ្វើប្រព្រឹកម្មសំណល់។

## III. គោលការណ៍ណែនាំ ស្តីពី ការរៀបចំផែនការគ្រប់គ្រងសំណល់រឹង

### ១. គោលបំណង

គោលបំណងនៃគោលការណ៍ណែនាំនេះគឺ ដើម្បីឱ្យដំណើរការប្រគ្រងសំណល់មានផែនការគ្រប់គ្រងច្បាស់លាស់ ដោយក្នុងនេះបានគិតគូរទៅដល់ ការកាត់បន្ថយបរិមាណសំណល់ ការប្រើប្រាស់ឡើងវិញ ការកែច្នៃ និងការទុកដាក់សំណល់រឹងប្រកបដោយសុវត្ថិភាព។

### ២. ការរៀបចំផែនការគ្រប់គ្រងសំណល់រឹង

[១] អ្នកដែលមានកាតព្វកិច្ចរៀបចំផែនការគ្រប់គ្រងសំណល់រឹងគ្រប់ប្រភេទមាន៖

ក) អាជ្ញាធរដែនដីថ្នាក់ខេត្ត-ក្រុង ត្រូវរៀបចំផែនការ (ប្លង់មេ) គ្រប់គ្រងសំណល់នៅក្នុងខេត្ត-ក្រុងរបស់ខ្លួនសំរាប់រយៈពេលមធ្យម និងរយៈពេលវែង។

ខ) រោងចក្រ សហគ្រាស មន្ទីរពេទ្យ ពហុព្យាបាល មណ្ឌលសុខភាព ផ្សារទំនើប សកលវិទ្យាល័យ ផ្ទះសំណាក់ សណ្ឋាគារ មានភារកិច្ចរៀបចំផែនការគ្រប់គ្រងសំណល់រឹងរបស់ខ្លួន សំរាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីចូលរួមក្នុងការគ្រប់គ្រងសំណល់រឹងប្រកបដោយប្រសិទ្ធភាព ដោយមានរៀបចំនូវយុទ្ធសាស្ត្រ ក្នុងការអនុវត្តន៍ផែនការគ្រប់គ្រងសំណល់។

[២] កាតព្វកិច្ចរបស់អ្នករៀបចំផែនការដែលមានចែងនៅក្នុងចំនុច ១ ខ) ខាងលើ ត្រូវ ÷

ក) រៀបចំផែនការគ្រប់គ្រងសំណល់រឹងសំរាប់រយៈពេលប្រាំឆ្នាំម្តង ហើយបញ្ជូនផែនការនោះទៅក្រសួងបរិស្ថាន និងអាជ្ញាធរដែនដី តាមរយៈមន្ទីរបរិស្ថាន។

ខ) ផ្តល់របាយការណ៍អំពីការគ្រប់គ្រងសំណល់រឹងសំរាប់ឆ្នាំកន្លងមក ដែលក្នុងនោះមានបរិយាយអំពីប្រភេទ បរិមាណសំណល់ ព្រមទាំងលំហូរសំណល់ទៅក្រសួងបរិស្ថាន និងអាជ្ញាធរដែនដី ជារៀងរាល់ដើមឆ្នាំបន្ទាប់។

គ) ត្រូវបញ្ជូនរបាយការណ៍អំពីការអនុវត្តន៍ផែនការប្រចាំឆ្នាំរបស់ខ្លួនទៅមន្ទីរបរិស្ថាន និងអាជ្ញាធរដែនដីខេត្ត-ក្រុងដើម្បីផ្ទៀងផ្ទាត់និងវាយតំលៃ។

[៣] អាជ្ញាធរដែនដីត្រូវធ្វើការទំនាក់ទំនងជាមួយតំបន់ ឬខេត្តនៅជាប់ព្រំប្រទល់ដែលមានកន្លែងធ្វើប្រព្រឹត្តកម្ម និងទីលានចាក់សំណល់រឹងចោលចំពោះតំបន់ដែលមានប្រជាជនរស់នៅតិចតួច ដើម្បីសហការរៀបចំប្លង់មេគ្រប់គ្រងសំណល់រឹងរួមគ្នាមួយ។

## ៣. និន្ន័យ និងទិន្នន័យបែបបទរៀបចំផែនការគ្រប់គ្រងសំណល់រឹង

### ៣.១ ទិន្នន័យនៅក្នុងផែនការគ្រប់គ្រងសំណល់រឹង

អ្នករៀបចំផែនការគ្រប់គ្រងសំណល់រឹង ទាំងសំរាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង មានភារកិច្ចបំពេញនូវទិន្នន័យដូចមានចែងខាងក្រោមនេះ ÷

[១] ត្រូវកំណត់អំពីប្រភេទ និងបរិមាណសំណល់ប្រកបដោយគ្រោះថ្នាក់ និងសំណល់មិនបង្កគ្រោះថ្នាក់ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ១។

[២] រៀបរាប់វិធានការអនុវត្តន៍ក្នុងការទប់ស្កាត់ការបង្កើតសំណល់ ការកាត់បន្ថយបរិមាណសំណល់ ការប្រើប្រាស់ឡើងវិញ ការកែច្នៃ និងការទុកដាក់សំណល់រឹងប្រកបដោយសុវត្ថិភាព។

[៣] ត្រូវរាយការណ៍ពីទិន្នន័យទីលានដែលឆ្លើយតបគោលការណ៍ណែនាំទីលាន ទៅមន្ទីរបរិស្ថានខេត្ត-ក្រុង ដើម្បីសុំការអនុញ្ញាត ក្នុងករណីមានទីលានសំរាប់ចាក់ចោលសំណល់ខ្លួនឯង។

[៤] ត្រូវមានរបាយការណ៍បកស្រាយចំណុចខ្វះខាតទាក់ទងទៅនឹងការអនុវត្តន៍ ក្នុងការចាក់ចោលសំណល់ ជាពិសេសកង្វះខាតទៅលើការប្រើប្រាស់មធ្យោបាយដែលមាន។

[៥] ត្រូវអនុវត្តតាមអនុក្រឹត្យលេខ ៣៦ អនក្រ.បក ក្នុងករណីមានការនាំចេញសំណល់រឹងពីព្រះរាជាណាចក្រកម្ពុជាទៅប្រទេសដទៃទៀត។ ការនាំចេញសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុលោមតាមបទបញ្ញត្តិ នៃអនុសញ្ញាបាសែលស្តីពីការត្រួតពិនិត្យ ការដឹកជញ្ជូនអន្តរជាតិ និងការបោះបង់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ឆ្នាំ១៩៨៩ ដែលចូលជាធរមាននៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៩២។

### ៣.២ ប្រភេទ បរិមាណ និងប្រភពសំណល់

[១] អ្នកមានភារកិច្ចរៀបចំផែនការគ្រប់គ្រងសំណល់រឹងត្រូវធ្វើរបាយការណ៍ស្តីពី÷

ក) ប្រភេទនិងបរិមាណសំណល់ប្រកបដោយគ្រោះថ្នាក់ និងសំណល់មិនបង្កគ្រោះថ្នាក់ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ១។

ខ) ប្រភពសំណល់ គឺសំដៅទៅលើប្រភេទសំណល់ដែលបានលើកឡើងនៅចំណុចខាងលើ។

គ) កាលបរិច្ឆេទនៃការបង្កើតសំណល់។

[២] បរិមាណសំណល់ត្រូវគិតជាតោន។

## ៣.៣ សំរាមសំណល់

[១] អ្នកមានកាតព្វកិច្ចរៀបចំផែនការគ្រប់គ្រងសំណល់រឹងត្រូវមានការចាត់ចែង ទុកដាក់ ដឹកជញ្ជូន និងនិតិវិធីក្នុងការចាក់ចោលសំណល់ ដោយប្រើប្រាស់បច្ចេកទេសសមស្របទៅនឹងការអនុវត្តន៍ជាក់ស្តែងយោងតាមឧបសម្ព័ន្ធ ២ ហើយធ្វើយ៉ាងណាមិនត្រូវឱ្យមានការប៉ះពាល់សុខភាពមនុស្ស សត្វ និងគុណភាពបរិស្ថាន។

[២] ទីលានចាក់សំណល់ ត្រូវមានទិន្នន័យដូចខាងក្រោមនេះ÷

ក) ម្ចាស់ ឬអ្នកគ្រប់គ្រងទីលាន

ខ) អាស័យដ្ឋាន និងប្រភេទទីលាន

គ) ច្បាប់អនុញ្ញាតឱ្យប្រើប្រាស់ទីលាន។

[៣] អ្នកមានកាតព្វកិច្ចរៀបចំផែនការគ្រប់គ្រងសំណល់រឹង ត្រូវអនុវត្តនិតិវិធីក្នុងការទប់ស្កាត់ការបង្កើតសំណល់ ការកាត់បន្ថយបរិមាណសំណល់ ការប្រើប្រាស់ឡើងវិញ ការកែច្នៃសំណល់ យោងតាមឧបសម្ព័ន្ធ ៣ ដោយធ្វើយ៉ាងណាមិនត្រូវឱ្យមានការប៉ះពាល់សុខភាពប្រជាពលរដ្ឋ និងប៉ះពាល់បរិស្ថាន។

[៤] ក្នុងករណីមានការនាំចេញសំណល់រឹងទៅក្រៅព្រះរាជាណាចក្រកម្ពុជាត្រូវគោរពតាមចំណុច [៥] ក្នុងលេខ៣.១ នៃគោលការណ៍ណែនាំនេះ។

## ៣.៤ ទិដ្ឋភាព

[១] អ្នកដែលមានកាតព្វកិច្ចរៀបចំផែនការគ្រប់គ្រងសំណល់រឹង ត្រូវពន្យល់នូវវិធានការនិមួយៗ ព្រមទាំងមូលហេតុច្បាស់លាស់ក្នុងការអនុវត្តវិធានការទប់ស្កាត់ការបង្កើតសំណល់ ការកាត់បន្ថយបរិមាណសំណល់ ការប្រើប្រាស់ឡើងវិញ ការកែច្នៃ និងការទុកដាក់សំណល់រឹងប្រកបដោយសុវត្ថិភាព។

[២] ក្នុងករណីដែលមានកន្លែងចាក់ចោលសំណល់ (ទីលាន) ដោយខ្លួនឯង អ្នកគ្រប់គ្រងសំណល់ត្រូវធ្វើការសាងសង់ទីលាន ដោយគោរពតាមគោលការណ៍ណែនាំការសាងសង់និងការគ្រប់គ្រងទីលាន។

## ៣.៥ ទំរង់បែបបទនៃការសរសេរគំរោងផែនការ

ទំរង់បែបបទក្នុងការរៀបចំគំរោងផែនការគ្រប់គ្រងសំណល់រឹង÷

[១] ត្រូវអនុវត្តតាមឧបសម្ព័ន្ធ ៤។

[២] ត្រូវរៀបចំឯកសារជាភាសាខ្មែរ មើលដាច់ សរសេរដោយមាស៊ីនអង្គុលីលេខ ឬ កំព្យូទ័រ។

## ៣.៦ ការច្របាច់ផែនការចូលគ្នា

អ្នកដែលមានកាតព្វកិច្ចរៀបផែនការគ្រប់គ្រងសំណល់រឹងអាចអនុញ្ញាតឱ្យច្របាច់ផែនការបញ្ចូលគ្នាតែមួយតាមសំណើប្រសិនបើ ÷

ក) មានការបញ្ចេញសំណល់ប្រភេទស្រដៀងគ្នា

ខ) មានសកម្មភាពនៅក្នុងសង្កាត់ ឬឃុំតែមួយជាមួយគ្នា និង

គ) មានប្រភពបញ្ចេញសំណល់ពីសកម្មភាពសេដ្ឋកិច្ចស្រដៀងគ្នា។

## ៣.៧ ព័ត៌មានសំខាន់ៗដែលត្រូវការសំរាប់រៀបចំផែនការគ្រប់គ្រងសំណល់រឹង

ក្នុងការរៀបផែនការគ្រប់គ្រងសំណល់រឹងសំរាប់មូលដ្ឋានដូចជាសហគមន៍ អាជ្ញាធរតាមខេត្ត ក្រុង ចាំបាច់ត្រូវដឹងពីព័ត៌មានសំខាន់ៗដូចខាងក្រោម÷

[១] ហេដ្ឋារចនាសម្ព័ន្ធតំបន់បញ្ចេញសំណល់ ដូចជាចំនួននិងកំនើនប្រជាជន កំណើនសេដ្ឋកិច្ច ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍។

[២] ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំណល់ ដូចជាការគ្រប់គ្រង ការប្រមូលនិងដឹកជញ្ជូន ការចាក់ចោល គោលការណ៍ជៀសវាងបង្កើតសំណល់ ឬគោលការណ៍កាត់បន្ថយ គោលការណ៍ប្រើប្រាស់ឡើងវិញ និងគោលការណ៍កែច្នៃ។

## IV. គោលការណ៍ណែនាំ ស្តីពី ការសាងសង់ និងការគ្រប់គ្រងទីលាន

### ១. គោលបំណង

[១] កាត់បន្ថយឱ្យដល់កំរិតអប្បបរមា ដែលអាចធ្វើទៅបាន នូវហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន តាមរយៈការយកសំណល់ទៅចាក់សំណល់ចោលនៅទីលាន។

[២] ថែរក្សាគុណភាពទឹកក្រោមដី ទឹកលើដី ខ្យល់ (បរិយាកាស) និងកាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់។

[៣] កាត់បន្ថយបរិមាណសំណល់ និងហេតុប៉ះពាល់អវិជ្ជមានដែលចេញពីសំណល់ដូចជាទឹកសំអុយ និងឧស្ម័នទីលានតាមរយៈការធ្វើប្រព្រឹត្តកម្មសំណល់ និងការញែកសំណល់ផងដែរ។

[៤] ធានាមិនឱ្យមានគ្រោះថ្នាក់ដល់សុខភាពប្រជាពលរដ្ឋ ធម្មជាតិ សត្វ នៅក្នុងពេលដំណើរការ និងក្រោយពេលបិទទីលាន។

[៥] ផ្តល់ព័ត៌មាន និងអនុសាសន៍បច្ចេកទេស ស្តីពី ការសាងសង់ កិច្ចដំណើរការទីលាន និងការចាក់ចោលសំណល់ ការបិទទីលាន និងការគ្រប់គ្រងបន្ត ដើម្បីធានាសុវត្ថិភាពសុខភាពសាធារណៈ និងការពារបរិស្ថាន។

### ២. ប្រភេទទីលាន

យោងតាមស្ថានភាពបច្ចុប្បន្ននៃព្រះរាជាណាចក្រកម្ពុជា ទីលានសំរាប់ចាក់សំណល់រឹងអាចចែកជាបីប្រភេទផ្សេងៗគ្នា ÷

[១] **ទីលានបទដ្ឋានសាមញ្ញ** (basic standard landfill) ជាទីលានដែលសាងសង់ឡើងសំរាប់តែចាក់ចោលសំណល់រឹងមិនបង្កគ្រោះថ្នាក់ (មើលឧបសម្ព័ន្ធ ៥) ដោយអាចអនុញ្ញាតឱ្យសាងសង់ទៅតាមបទដ្ឋានកំរិតសាមញ្ញ (តែត្រូវធ្វើយ៉ាងណាមិនឱ្យមានការប៉ះពាល់បរិស្ថាន) និងបានតែនៅតាមតំបន់ដែលមិនមែនជាតំបន់ឧស្សាហកម្មប៉ុណ្ណោះ។

[២] **ទីលានអនាម័យ** (stanitary landfill) ជាទីលានដែលសាងសង់ឡើងសំរាប់តែចាក់ចោលសំណល់រឹងទូទៅមិនគ្រោះថ្នាក់ (ឧបសម្ព័ន្ធ ៥) ហើយអនុញ្ញាតឱ្យសាងសង់នៅតាមទីរួមខេត្ត-ក្រុង និងតំបន់ឧស្សាហកម្ម។

[៣] **ទីលានសំរាប់សំណល់ប្រកបដោយគ្រោះថ្នាក់** ជាទីលានដែលសាងសង់ឡើងសំរាប់ដាក់តែសំណល់រឹងប្រកបដោយគ្រោះថ្នាក់ (ឧបសម្ព័ន្ធ ៥)។

## ៣. តំរូវការទីលាន

### ៣.១ លក្ខខណ្ឌនៃទីលាន

ដូចមានចែងនៅក្នុងចំណុច២ ស្តីពី ប្រភេទទីលាន ទីលានសំរាប់ចាក់ចោលសំណល់ចែកចេញជាបីប្រភេទ។ តំរូវការសំរាប់សាងសង់ និងគ្រប់គ្រងទីលានបទដ្ឋានសាមញ្ញ គឺ ស្ថិតនៅកំរិតមួយទាបបំផុត តែក៏តំរូវឱ្យមានការត្រួតពិនិត្យនិងមានការអនុញ្ញាត។ ចំណែកតំរូវការសំរាប់សាងសង់និងគ្រប់គ្រងទីលានអនាម័យ និងទីលានសំរាប់សំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវគោរពតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវ។

ការសាងសង់ទីលានអាចស្ថិតនៅចន្លោះទីលានបទដ្ឋានសាមញ្ញ និងទីលានអនាម័យអាស្រ័យទៅតាមស្ថានភាពជាក់ស្តែង តែត្រូវមានការត្រួតពិនិត្យនិងយល់ព្រមពីសមត្ថកិច្ចជំនាញ និងអាជ្ញាធរដែនដីខេត្ត-ក្រុង។ នៅពេលសាងសង់ទីលានអាជ្ញាធរមានសមត្ថកិច្ចខេត្ត-ក្រុងមានតួនាទីត្រួតពិនិត្យ។

### ៣.២ តំរូវការចាំបាច់សំរាប់ទីលានបទដ្ឋានសាមញ្ញ

[១] ត្រូវបាំងដោយរបង ជៀសវាងការរសាត់សំណល់ចេញទៅក្រៅ និងការចូលក្នុងទីលានដោយគ្មានការអនុញ្ញាតហើយ នៅផ្នែកខាងក្នុងរបងត្រូវដាំដើមឈើបន្ថែម។

[២] រៀបចំទីធ្លាទីលានទាំងមូលឱ្យបានរាបស្មើ។ ទីតាំងទីលានទាំងមូលត្រូវលើកឱ្យមានកំពស់ ០,៥ម៉ែត្រ ខ្ពស់ជាងបរិវេណជុំវិញ ដោយមានរៀបចំក្រាលបាតទីលានដូចមានចែងក្នុងឧបសម្ព័ន្ធ ៦ ហើយត្រូវរៀបចំយ៉ាងហោចឱ្យមានជំរាលធំជាងឬស្មើ ១ ភាគរយ ពីម្ខាងទៅម្ខាង ដូចមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ៦។

[៣] ត្រូវមានប្រព័ន្ធផ្លូវសំរាប់ដឹកជញ្ជូនសំណល់ចូលទៅកាន់ទីលានរហូតដល់កន្លែងចាក់សំណល់ ដោយធានានូវគុណភាពសំរាប់រថយន្តដឹកជញ្ជូនសំណល់គ្រប់ប្រភេទ និងប្រើប្រាស់បានគ្រប់រដូវ។

[៤] ត្រូវសាងសង់ការិយាល័យគ្រប់គ្រងនៅក្បែរផ្លូវចូលទីលាន ហើយត្រូវមានឃ្លាំងបន្ទប់ទឹក មានមធ្យោបាយការពារសុវត្ថិភាព ឧបករណ៍ពន្លត់អគ្គីភ័យ និងមធ្យោបាយត្រួតពិនិត្យអង្កេត។

[៥] ត្រូវរៀបចំឱ្យមានកន្លែងចាក់ចោលសំណល់ចុងក្រោយ (dumping area)។

[៦] ត្រូវមានអាងស្តុកទឹកសំអុយមួយដែលនៅខាងទំនាបនៃទីលានដូចមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ៦។

[៧] ត្រូវកត់ត្រាទិន្នន័យនៃបរិមាណសំណល់ ឬមាឌសំណល់ដូចមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ៦ ដែលរៀបចំឡើងដោយបុគ្គលិកទទួលការបណ្តុះបណ្តាល។

[៨] មិនអនុញ្ញាតឱ្យអ្នករើសអេតចាយចូលក្នុងទីលានដោយគ្មានការអនុញ្ញាតជាមុន។

[៩] ត្រូវជៀសវាងមិនឱ្យមានការឆេះសំណល់ឡើយ។

[១០] ត្រូវចាក់សំណល់គរមិនឱ្យរលំ ឬភ្លូលដាល ដូចមានបង្ហាញជាអនុសាសន៍នៅក្នុងឧបសម្ព័ន្ធ ៦។

## ៣.៣ តំរូវការចាំបាច់សំរាប់ទីលានអនាម័យ

[១] ត្រូវបំពេញល័ក្ខខ័ណ្ឌចំណុច [១] [៣] [៤] [៥] [៨] [៩] និង [១០] ខាងលើក្នុងលេខ ៣.២។

[២] ត្រូវធ្វើទ្រនាប់បាតក្រោមទីលានតាមបទដ្ឋានបច្ចេកទេសសមស្រប ដូចមានបង្ហាញជាអនុសាសន៍នៅក្នុងឧបសម្ព័ន្ធ ៦។

[៣] ត្រូវរៀបចំប្រព័ន្ធប្រមូល និងប្រព្រឹត្តកម្មទឹកសំអុយទីលាន។ ប្រព័ន្ធប្រមូល និងប្រព្រឹត្តកម្មឧស្ម័នទីលានគួរតែ ធ្វើការគិតគូររៀបចំឡើងដូចមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ៦។

[៤] ត្រូវមានជញ្ជីងថ្លឹងគណនាបរិមាណសំណល់ដែលយកមកចាក់លើទីលាន។

[៥] ក្នុងករណីដែលអាចធ្វើទៅបាន គប្បីឱ្យមានការធ្វើប្រព្រឹត្តកម្មបឋមទៅលើសំណល់ (ឧទាហរណ៍ដោយប្រើបច្ចេកទេសសាមញ្ញបំផុត នៅមួយកន្លែងដោយប្រើប្រព័ន្ធបញ្ចូលខ្យល់តាមបែបអ៊ែរ៉ូបិក) ដើម្បីកាត់បន្ថយបរិមាណសំណល់ បរិមាណទឹកសំអុយទីលាន និងធ្វើឱ្យគំនរសំណល់មានលំនឹងល្អ។

## ៤. ល័ក្ខខ័ណ្ឌនានាដើម្បីសុំការអនុញ្ញាត

សមត្ថកិច្ចជំនាញ និងអាជ្ញាធរដែនដីខេត្ត ក្រុងត្រូវធ្វើការសិក្សា និងវាយតំលៃហេតុប៉ះពាល់បរិស្ថាន មុនអនុញ្ញាតឱ្យសាងសង់និងដំណើរការទីលាន។ អ្នកដែលសុំការអនុញ្ញាតត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម៖

[១] ត្រូវមានពាក្យសុំការអនុញ្ញាតដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណអ្នកសុំ និងអ្នកគ្រប់គ្រង ក្នុងករណីជាមនុស្សផ្សេងគ្នា។

[២] ត្រូវអធិប្បាយអំពីប្រភេទ និងបរិមាណសំណល់ដែលត្រូវចាក់ចោលលើទីលាន។

[៣] ត្រូវបង្ហាញពីសមត្ថភាពទីលានក្នុងការទទួលសំណល់។

[៤] ត្រូវអធិប្បាយពីទំហំទីលាន ស្ថានភាពភូគព្ភសាស្ត្រ និងធារាសាស្ត្រ ព្រមទាំងបច្ចេកទេសសាងសង់។

[៥] ត្រូវអធិប្បាយពីមធ្យោបាយការពារ និងកាត់បន្ថយការបំពុល។

[៦] ត្រូវអធិប្បាយពីផែនការគ្រប់គ្រង ត្រួតពិនិត្យ និងអង្កេតទីលានដូចមានបង្ហាញជាអនុសាសន៍នៅក្នុងឧបសម្ព័ន្ធ ៦។

## ៥. សំណល់ដែលមិនអនុញ្ញាតឱ្យចាក់ចោលលើទីលានបនដ្ឋានសាមញ្ញ និងទីលានអនាម័យ

[១] ដោយការធ្វើជីកំប៉ុស្តិ៍ជាអនុសាសន៍ងាយស្រួលមួយ និងមានប្រសិទ្ធភាពក្នុងការកាត់បន្ថយបរិមាណសំណល់ ដូចនេះសំណល់ជីវៈ គួរតែបង្វែរទៅទីលានធ្វើជីកំប៉ុស្តិ៍ឱ្យបានដល់កំរិតអតិបរមាដែលអាចធ្វើទៅបាន។

សំរាប់ប្រាំឆ្នាំដំបូង ក្រោយពេលដែលគោលការណ៍ណែនាំនេះបានចេញប្រកាស សំណល់ដែលអាចធ្វើការបំបែកធាតុក្រោមអំពើជីវៈ អាចឱ្យចាក់ចោលលើទីលាន ៩០ភាគរយនៃទួរលេខក្រោយបង្អស់ ស្ដីពី បរិមាណសំណល់ ហើយ ៧០ភាគរយ មិនអោយលើសពីដប់ឆ្នាំដំបូង។

ក្រោយពីមុនគោលការណ៍ណែនាំបានយកទៅអនុវត្តបាន៥ឆ្នាំ អាជ្ញាធរបរិស្ថានខេត្ត ក្រុងត្រូវគិតគូរសារឡើងវិញ អំពីមុខសញ្ញាខាងលើ ដោយប្រើបាយការណ៍អ្នកដែលជាប់ពាក់ព័ន្ធការងារគ្រប់គ្រងសំណល់។

[២] សំណល់រាវ និងសំណល់ស្រដៀងសំណល់ភក់។

[៣] សំណល់ដែលមិនស្គាល់ មិនដឹងពីភាពគ្រោះថ្នាក់ (ដូចជាសំណល់ដែលចេញពីមន្ទីរពិសោធន៍)។

[៤] សាកសពមនុស្ស សត្វ។

[៥] សំណល់សំបកកង់យានយន្តគ្រប់ប្រភេទ (សំបកកង់ កង់ ម៉ូតូ សំបកកង់ឡាន)។

[៦] សំណល់គ្រឿងអេឡិកត្រូនិកមិនអនុញ្ញាតឱ្យចាក់នៅទីលានបទដ្ឋានសាមញ្ញទោះបីជាបានធ្វើការកែច្នៃរួចក៏ដោយ។ នៅទីលានបទដ្ឋានសាមញ្ញត្រូវមានកន្លែងទុកដាក់បណ្តោះអាសន្ន ប្រភេទសំណល់នេះក្នុងករណីមានបរិមាណតិចតួចមុនពេលដឹកយកទៅចាក់ចោលទីលានអនាម័យ។

[៧] សំណល់វេជ្ជសាស្ត្រ ប្រភេទ ខ និង គ (ឧបសម្ព័ន្ធ ១០) ដែលមិនបានយកទៅធ្វើប្រព្រឹត្តកម្មជាមុន។

[៨] សំណល់មានសារធាតុផ្ទុះនិងបង្កចំហេះ។

## ៦. លក្ខខណ្ឌក្នុងការជ្រើសរើសទីតាំងសាងសង់ទីលាន

[១] ទីលានបទដ្ឋានសាមញ្ញ និងអនាម័យត្រូវតែសាងសង់ឱ្យបានឆ្ងាយពីផ្លូវជាតិ និងផ្ទះប្រជាជន ឬតំរោងសំណង់ផ្ទះប្រជាជនយ៉ាងតិច ៥០០ម៉ែត្រ។

ការជ្រើសរើសទីតាំងសំរាប់ទីលានសំណល់ប្រកបដោយគ្រោះថ្នាក់ គឺជាសេចក្តីសំរេចរបស់ក្រសួងបរិស្ថាន។ ដូចមានចែងខាងលើទីលានសំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវនៅចំងាយពីផ្លូវជាតិនិងពីទីប្រជុំជនយ៉ាងហោច ១០០០ម៉ែត្រ។

[២] ទីលានទាំង៣ប្រភេទ ត្រូវមានទីតាំងយ៉ាងតិច ១០០០ម៉ែត្រពី÷

- តំបន់រមណីយដ្ឋាន
- ផ្លូវទឹក បឹង ទន្លេ
- កន្លែងគោរពបូជា និងបេតិកភ័ណ្ឌជាតិ (ធម្មជាតិ និងវប្បធម៌)។

[៣] ទីលាន ត្រូវនៅចំងាយយ៉ាងតិច ៥០០០ម៉ែត្រ ពីព្រលានយន្តហោះ។

[៤] ទីលានមិនត្រូវសាងសង់នៅតំបន់ទំនាប ដែលមិនអាចបង្ហូរទឹកសំអុយចេញពីទីលានបាន។

[៥] ទីលានមិនត្រូវសាងសង់នៅតំបន់លិចទឹក។

[៦] ទីលាន ត្រូវជ្រើសរើសយកតំបន់ដែលមានល័ក្ខខ័ណ្ឌភូគព្ភសាស្ត្រ និងធារាសាស្ត្រអនុគ្រោះ ដូចមានបង្ហាញជាអនុសាសន៍នៅក្នុងឧបសម្ព័ន្ធ ៦។

[៧] ទីលានអនាម័យ និងទីលានចាក់សំណល់ប្រកបគ្រោះថ្នាក់ចាំបាច់ត្រូវមានរៀបចំទ្រនាប់ក្រាលបាត ជៀសវាងនូវហេតុប៉ះពាល់ជាអវិជ្ជមានដល់គុណភាពទឹកក្រោម

ដី និងត្រូវធ្វើការសិក្សាពីលក្ខណៈភូគព្ភសាស្ត្រ ដូចមានបង្ហាញជាអនុសាសន៍នៅក្នុងឧបសម្ព័ន្ធ ៦។

## ៧. ប្រព័ន្ធប្រមូលឧស្ម័ន និងទឹកសំអុយទីលាន

[១] ទីលានអនាម័យនិងទីលានសំណល់ប្រកបដោយគ្រោះថ្នាក់ ប្រព័ន្ធប្រមូលឧស្ម័នទីលានត្រូវសាងសង់ឱ្យបានត្រឹមត្រូវ តាមបទដ្ឋានបច្ចេកទេសដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ៦ ជាអនុសាសន៍។

[២] ទីលានបទដ្ឋានសាមញ្ញ ទាំងការសាងសង់ទ្រនាប់បាតទីលាន និងអាងស្តុកទឹកសំអុយទីលាន ត្រូវគិតអំពីជំរាលដោយអនុវត្តដូចការណែនាំមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ៦ ជាអនុសាសន៍។

[៣] ទីលានអនាម័យ និងទីលានសំណល់ប្រកបដោយគ្រោះថ្នាក់ ប្រព័ន្ធប្រមូល និងប្រព្រឹត្តកម្មទឹកសំអុយទីលាន ត្រូវសាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ៦ ជាអនុសាសន៍។

## ៨. ដំណើរការទីលាន

### ៨.១ រចនាសម្ព័ន្ធដឹកនាំ

[១] ត្រូវមានការបែងចែកជាក្រុមការងារ ជាពិសេសត្រូវមានក្រុមត្រួតពិនិត្យមួយ ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការពិនិត្យរាល់ការមកដល់នៃសំណល់។

[២] ត្រូវរៀបចំរចនាសម្ព័ន្ធដឹកនាំមួយ ដែលមានបញ្ជាក់ពីភារកិច្ចនិងការទទួលខុសត្រូវ ហើយថ្នាក់ដឹកនាំក្រុមមួយៗ ត្រូវកំណត់ពីភារកិច្ចនិងតួនាទីព្រមទាំងឈ្មោះដូចមានចែងក្នុងអនុសាសន៍ឧបសម្ព័ន្ធ ៦។ ឯកសាររចនាសម្ព័ន្ធដឹកនាំនេះត្រូវបញ្ជូនទៅអាជ្ញាធរខេត្ត ក្រុងក្នុងករណីមានការស្នើសុំ។

### ៨.២ ការគ្រប់គ្រងសំណល់នាំចូលទីលានដាំងមីប្រភេទ

[១] រាល់សំណល់ដឹកចូលត្រូវមានលិខិតត្រឹមត្រូវ ដែលមានបញ្ជាក់ពីប្រភពសំណល់។ ត្រូវពិនិត្យផ្ទៀងផ្ទាត់ផ្ទាល់ភ្នែកនៅច្រកចូល ធ្វើការថ្លឹង ការកំណត់បរិមាណ និងមាឌ ព្រមទាំងកត់ត្រាជាប្រចាំ និងចងក្រងជាឯកសារ។ ឯកសារទាំងនោះជាប្រភពទុនមួយសំរាប់ជាមូលដ្ឋានរៀបចំផែនការគ្រប់គ្រងសំណល់នៅថ្ងៃអនាគត។

ឯកសារនេះត្រូវបញ្ជូនទៅមន្ទីរបរិស្ថានខេត្ត-ក្រុងក្នុងមួយត្រីមាសម្តង។

[២] រាល់សកម្មភាពនៅលើទីលានត្រូវមានការត្រួតពិនិត្យ អង្កេត តាមដានឱ្យបានទៀងទាត់ និងចងក្រងជាឯកសារដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ៦។

[៣] ចំពោះសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវធ្វើការត្រួតពិនិត្យឱ្យបានហ្មត់ចត់នៅពេលដឹកចូលក្នុងទីលាន ត្រូវត្រួតពិនិត្យរាល់ឯកសារ និងកត់ត្រាឱ្យបានច្បាស់លាស់ពីប្រភពសំណល់ ម្ចាស់សំណល់ និងក្រុមហ៊ុនប្រមូលដឹកជញ្ជូនក៏ដូចជាភាពពុល និងប្រភេទនៃសំណល់ ដើម្បីជៀសវាងមានការក្លែងបន្លំ។

[៤] ក្នុងករណីដែលមានការរកឃើញមានសំណល់ប្រកបដោយគ្រោះថ្នាក់បន្លំយកទៅចាក់ចោលនៅលើទីលានបទដ្ឋានសាមញ្ញ ឬទីលានអនាម័យ សំណល់នោះត្រូវឃាត់និងរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព ហើយផ្តល់ព័ត៌មានដល់អាជ្ញាធរបរិស្ថានខេត្ត-ក្រុងជាបន្ទាន់។ អាជ្ញាធរបរិស្ថានខេត្ត-ក្រុង ត្រូវសំរេចបញ្ជូនសំណល់នោះទៅកន្លែងទីលានសំរាប់សំណល់ប្រកបដោយគ្រោះថ្នាក់។

[៥] ក្នុងករណីមានការរកឃើញថាអ្នកគ្រប់គ្រងទីលានបទដ្ឋានសមញ្ញ ឬទីលានអនាម័យអនុញ្ញាតឱ្យមានការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់នៅលើទីលានរបស់ខ្លួន អ្នកនោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

## ៨.៣ បុគ្គលិកធ្វើការនៅទីលានចាក់សំរាម

### [១] លក្ខខណ្ឌទូទៅ

ក្នុងកិច្ចដំណើរការទីលានត្រូវមានបុគ្គលិកគ្រប់គ្រាន់ គ្រប់ពេលវេលាព្រមទាំងប្រកបដោយសមត្ថភាព និងមានការទទួលខុសត្រូវខ្ពស់។ រាល់បុគ្គលិកទាំងអស់ត្រូវបានទទួលការហ្វឹកហ្វឺនអប់រំជាបន្តបន្ទាប់។

### [២] បុគ្គលិកដែលមានតួនាទី

ក) បុគ្គលិកដែលមានតួនាទីទទួលខុសត្រូវតាមផ្នែកនិមួយៗ ត្រូវមានសមត្ថភាពផ្នែកបច្ចេកទេសគ្រប់គ្រាន់អាចទុកចិត្តបាន និងមានបទពិសោធន៍ល្អក្នុងការងារចាប់តាំងពីកិច្ចដំណើរការសាងសង់ទីលាននិងគ្រប់គ្រង។

ខ) បុគ្គលិកគ្រប់គ្រងត្រូវមានការទទួលខុសត្រូវក្នុងការណែនាំ និងផ្តល់ព័ត៌មានទៅបុគ្គលិកដទៃទៀតឱ្យបានទៀងទាត់។

[៣] **បុគ្គលិកជំនាញ**

បុគ្គលិកទាំងនោះត្រូវមានជំនាញបច្ចេកទេសដែលអាចទុកចិត្តបាន។ ជំនាញទាំងនោះមានដូចជាការផ្តល់សេវាកម្មនៅសហគមន៍ ការប្រតិបត្តិទីលាន និងការចាក់សំណល់នៅលើទីលានតាមបច្ចេកទេស ដែលទទួលការហ្វឹកហ្វឺន ឬមានបទពិសោធន៍ច្រើនឆ្នាំ។

## ៨.៤ ការត្រួតពិនិត្យគុណភាពទឹកក្រោមដី

[១] ដើម្បីធានាបានគុណភាពទឹកក្រោមដី អាជ្ញាធរបរិស្ថានខេត្ត ក្រុង មានតួនាទីធ្វើការអង្កេត ពិនិត្យ តាមដានគុណភាពទឹកក្រោមដី ដោយយកទៅធ្វើការវិភាគពីរដងក្នុងមួយឆ្នាំនៅមន្ទីរពិសោធន៍ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ។ អ្នកទទួលខុសត្រូវគ្រប់គ្រងទីលានមានកាតព្វកិច្ចបង់តំលៃធ្វើការវិភាគនេះ។

[២] អ្នកគ្រប់គ្រងទីលានមានកាតព្វកិច្ចរាយការណ៍ដល់អាជ្ញាធរបរិស្ថានខេត្ត ក្រុងនូវរាល់ហេតុ និងផលប៉ះពាល់បរិស្ថានដែលបាន និងអាចកើតមានឡើង។

[៣] ការណែនាំ ស្តីពី ការអង្កេត ពិនិត្យ តាមដាន គុណភាពទឹកក្រោមដីមាននៅក្នុងឧបសម្ព័ន្ធ ៦ ជាអនុសាសន៍។

# ៩. ការត្រួតពិនិត្យ និងការអង្កេត

## ៩.១ ពេលដំណើរការទីលាន

[១] ត្រូវរៀបចំធ្វើយ៉ាងណាកុំឱ្យមានការកកស្ទះយានយន្តដឹកសំណល់។

[២] ធ្វើបញ្ជីសារពើភ័ណ្ឌ។

[៣] ត្រួតពិនិត្យបរិមាណ និងសមាសធាតុសំណល់។

[៤] ត្រួតពិនិត្យគុណភាពទឹកក្រោមដីជៀសវាងការជ្រាបទឹកសំអុយទីលាន។

[៥] រៀបចំទីតាំងចាក់សំណល់ ដើម្បីងាយស្រួលក្នុងការចាក់និងបង្ហាប់សំណល់។

[៦] អង្កេតនិងត្រួតពិនិត្យសមាសភាពទឹកសំអុយទីលាន ដោយផ្ទៀងផ្ទាត់ទៅតាមតារាងឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពី ការត្រួតពិនិត្យការបំពុលទឹក។

### ៩.២ ក្រោយពេលបិទទីលាន

ត្រួតពិនិត្យការសាយភាយ និងការជ្រាបទឹកសំអុយ ព្រមទាំងចាត់វិធានការក្នុងករណីចាំបាច់ ដូចមាននៅក្នុងឧសម្ព័ន្ធ ៦ ជាអនុសាសន៍។

## ១០. ការគ្របទីលានបញ្ចប់ និងការគ្រប់គ្រងបន្ត

### ១០.១ ការគ្របចុងក្រោយ

ការគ្របទីលានចុងក្រោយត្រូវធ្វើឡើងយ៉ាងយូរបំផុត ៦ខែ ក្រោយពេលឈប់ប្រើប្រាស់ទីលាន ដោយត្រូវអនុវត្តតាមការណែនាំខាងក្រោម៖

[១] ត្រូវកិនបង្ហាប់សំណល់ដែលបានចាក់ក្រោយគេនៅលើទីលាន។

[២] លប់ដីពីលើដោយកិនបង្ហាប់ឱ្យបានកំរាស់យ៉ាងតិចបំផុត ១,៥ម៉ែត្រ ដើម្បីជៀសវាងទឹកភ្លៀងជ្រាបឆ្លងកាត់សំណល់ ហើយនិងអាចដាំស្មៅ ឬរុក្ខជាតិបាន ដូចមានការណែនាំក្នុងឧបសម្ព័ន្ធ ៦ជាអនុសាសសន៍។

[៣] ត្រួតពិនិត្យទឹកសំអុយនិងឧស្ម័នទីលានយ៉ាងតិចពីរដងក្នុងមួយឆ្នាំ រហូតដល់ពេលមានការកំណត់ច្បាស់លាស់ថា មិនមានការប៉ះពាល់ដល់បរិស្ថានទៀតឡើយ។

[៤] ថែរក្សារបងពទ្ធ័ជុំវិញទីលានឱ្យបានត្រឹមត្រូវ បើខូចត្រូវធ្វើការជួសជុលឡើងវិញ។

### ១០.២ ការដាំរុក្ខជាតិឡើងវិញ

អ្នកគ្រប់គ្រងទីលានមានកាតព្វកិច្ចដាំស្មៅ ឬរុក្ខជាតិពីលើដីដែលគ្របរួច ដើម្បីការពារការជ្រាបទឹកភ្លៀង និងរិចរិល។

## V. គោលការណ៍ណែនាំ ស្តីពី ការធ្វើជីកំប៉ុស្តិ៍

### ១. គោលបំណង

[១] ចូលរួមកាត់បន្ថយបរិមាណសំណល់ និងបង្កើនអាយុកាលទីលានដោយធ្វើការបង្វែរសំណល់ជីវៈពីការចាក់ចោលនៅទីលានចាក់សំរាម យកទៅធ្វើជីកំប៉ុស្តិ៍វិញ។

[២] កាត់បន្ថយបរិមាណទឹកសំអុយ និងឧស្ម័នជីវៈ ដើម្បីរួមចំណែកការពារហេតុប៉ះពាល់បរិស្ថាន។

[៣] ជំរុញឱ្យមានការយកចិត្តទុកដាក់ក្នុងការញែកសំណល់ជីវៈចេញពីសំណល់ផ្សេងទៀតនៅប្រភព ដើម្បីទាញយកវត្ថុធាតុដើមជាសំណល់ដែលអាចធ្វើជីកំប៉ុស្តិ៍បាន។ ធ្វើយ៉ាងនេះ គឺ ក្នុងបំណងកាត់បន្ថយសក្តានុពលសារធាតុពុលក្នុងជីកំប៉ុស្តិ៍។

[៤] បង្កើនគុណភាពដីកសិកម្មតាមរយៈការប្រើប្រាស់ជីកំប៉ុស្តិ៍ ធ្វើឱ្យប្រសើរឡើងនូវតួនាទីបរិស្ថាន និងគុណប្រយោជន៍របស់ដី។

### ២. វត្ថុធាតុដើមដែលអនុញ្ញាតឱ្យយកធ្វើជីកំប៉ុស្តិ៍

#### ២.១ លក្ខខណ្ឌទូទៅ

សំណល់ដែលអនុញ្ញាតឱ្យយកធ្វើជាវត្ថុធាតុដើម សំរាប់ធ្វើជីកំប៉ុស្តិ៍ លុះត្រាតែជាសំណល់ដែលអាចធ្វើការបំបែកធាតុក្រោមអំពើជីវៈបាន និងមិនមានផ្ទុកសមាសធាតុនាំអោយគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ គុណភាពទឹក និងដីក្នុងពេលធ្វើជីកំប៉ុស្តិ៍ ក៏ដូចជាពេលប្រើប្រាស់។

#### ២.២ សំណល់ជីវៈ (Bio-Waste)

សំណល់ជីវៈមានប្រភពមកពី៖

[១] **សំណល់ផ្ទះបាយ** សំណល់បន្លែ ផ្លែឈើ សាច់ សំបកស៊ុត កំទេចក្រដាសនិងកំទេចកាតុងតូចៗ។

[២] **សំណល់ទីផ្សារ** ដូចជាសំណល់បន្លែ ផ្លែឈើ សំណល់បៃតងផ្សេងៗទៀត។

[៣] **សំណល់សួនច្បារ** ស្មៅ ស្លឹកឈើ មែកឈើ។ល។

[៤] **សំណល់កសិកម្ម** សំណល់គ្រាប់ធញ្ញជាតិ មែកឈើ ចំបើង លាមកសត្វ។

[៥] **សំណល់ទីសត្តឃាត** អនុញ្ញាតតែសំណល់ពីសត្វដែលមិនមានជំងឺ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវត្រួតពិនិត្យនិងសំរេចបញ្ហានេះ។

[៦] **សំណល់ភក់ល្បាប់** ត្រូវគោរពតាមចំណុច ២.១ នៃល័ក្ខខ័ណ្ឌទូទៅ។

[៧] **ក្រដាសនិងកាតុង** ជាទូទៅគេត្រូវយកវាទៅធ្វើការកែច្នៃ។ ចំពោះក្រដាស ឬកាតុងដែលមានបរិមាណតិចតួច អនុញ្ញាតឱ្យយកមកលាយជាមួយនឹងសំណល់ជីវៈ ដើម្បីឱ្យវាជួយជក់ជាតិទឹក វាអាចជួយសំរួលដល់ដំណើរការធ្វើជីកំប៉ុស្តិ៍។ ក្រដាស ឬកាតុងដែលមានគុណភាព ឬរលោងមិនអនុញ្ញាតឱ្យយកធ្វើជាវត្ថុធាតុដើមធ្វើជីកំប៉ុស្តិ៍ឡើយ ទោះជាក្នុងកាលៈទេសៈណាក៏ដោយ។

[៨] **សំណល់ពីប្រព្រឹត្តកម្មអែនអែរ៉ូប៊ិក** ( digestate from anaerobic digestion ) ត្រូវគោរពតាមការណែនាំចំណុច ២.១ នៃល័ក្ខខ័ណ្ឌទូទៅ។

## ២.៣ ប្រភេទសំណល់ផ្សេងៗទៀត

សំណល់ផ្សេងៗទៀតដែលមិនបានរៀបរាប់ខាងលើ ហើយវាអាចធ្វើការបំបែកធាតុតាមជីវៈបាន អាចឱ្យដាក់លាយធ្វើជីកំប៉ុស្តិ៍បាន តែល្គិកណាវាបំពេញនូវល័ក្ខខ័ណ្ឌខាងក្រោមនេះ÷

[១] សំណល់អាចទទួលការបំបែកធាតុក្រោមអំពើមីក្រូសរីរាង្គ ឬដើរតួនាទីជាអ្នកបង្កឱ្យមានការបំបែកធាតុ និងដំណើរការធ្វើជីកំប៉ុស្តិ៍កាន់តែប្រសើរឡើង។

[២] សំណល់មិនមានសារធាតុពុលលើសពីការកំណត់មានចែងនៅក្នុងឧបសម្ព័ន្ធ ៧។

[៣] វត្ថុធាតុដើមដែលមិនធ្វើឱ្យផលិតផលជីកំប៉ុស្តិ៍ប៉ះពាល់ដល់សុខភាពមនុស្ស សត្វ រុក្ខជាតិ ដី ។ល។

## ២.៤ សំណល់ភក់

សំណល់ភក់ និងសំណល់កើតចេញពីការបំបែកធាតុតាមបែបអែនអែរ៉ូប៊ិក អាចអនុញ្ញាតឱ្យយកធ្វើជីកំប៉ុស្តិ៍បាន ប៉ុន្តែត្រូវវិភាគរកប៉ារ៉ាម៉ែត្រ សារធាតុពុលជាប្រចាំ ដោយគោរពតាមគោលការណ៍ណែនាំដូចមានចែងក្នុងឧបសម្ព័ន្ធ ៧។

បរិមាណរបស់សំណល់ភក់ដែលអនុញ្ញាតឱ្យយកធ្វើជាវត្ថុធាតុដើមបាន លុះត្រាតែវាមានភាពសំងួតរហូតដល់ ៣៥ភាគរយ។

## ៣. សារធាតុដែលមិនអនុញ្ញាតឱ្យយកធ្វើជាវត្ថុធាតុដើមធ្វើជីកំប៉ុស្តិ៍

[១] **ល័ក្ខខ័ណ្ឌទូទៅ** សារធាតុដែលមិនមានចែងក្នុងចំនុច ២.២ ស្តីពី វត្ថុធាតុដើមដែលអនុញ្ញាតឱ្យយកធ្វើជីកំប៉ុស្តិ៍ ឬវាមិនដើរតួនាទីជាកាតាលីករ ក្នុងដំណើរការ

ដូចមានចែងនៅក្នុង ២.៣ មិនអនុញ្ញាតឱ្យយកទៅធ្វើជីកំប៉ុស្តិ៍ឡើយ។

[២] សារធាតុដែលមានរៀបរាប់ដូចខាងក្រោម និងមានច្រើនជាងនេះទៀតមិនអនុញ្ញាតឱ្យយកធ្វើជីកំប៉ុស្តិ៍ ÷

- **សំណល់ភក់** ដែលមានសារធាតុបំពុលលើសពីការកំណត់ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ៧។
- **សំណល់ផេះ** ចេញពីឡដុតសំណល់មន្ទីរពេទ្យ និងឡដុតសំណល់ឧស្សាហកម្ម
- កែវ ប្លាស្ទិក កៅស៊ូ លោហៈ...មិនអាចឱ្យយកទៅធ្វើជីកំប៉ុស្តិ៍បានទេ ពីព្រោះវាមិនអាចធ្វើការបំបែកធាតុក្រោមអំពើជីវៈបាន។ តែបើនៅក្នុងវត្ថុធាតុដើមធ្វើជីកំប៉ុស្តិ៍ មានវត្ថុមានសារធាតុទាំងនេះ ស្ថិតនៅកំរិតអប្បបរមា និងជាកំទេចតូចៗដែលមាន ដោយសារពេលសកម្មភាពប្រមូលនិងដឹកជញ្ជូន វត្ថុធាតុដើមនេះអាចអនុញ្ញាតឱ្យយកធ្វើជីកំប៉ុស្តិ៍បានដែរ ហើយសារធាតុទាំងនោះត្រូវញែកវានៅពេលមុន និងក្រោយពេលដំណើរការធ្វើជីកំប៉ុស្តិ៍។

## ៤. ផលិតផលជីកំប៉ុស្តិ៍

### ៤.១ លក្ខខណ្ឌជីកំប៉ុស្តិ៍

ជីកំប៉ុស្តិ៍មិនមែនជាសំណល់ទៀតទេ វាជាផលិតផលដែលមានប្រយោជន៍ចំពោះជីកសិកម្ម ក្នុងលក្ខខណ្ឌប្រើប្រាស់សមស្របទៅតាមលក្ខណៈភូគ្រសាស្ត្រ។ ជីកំប៉ុស្តិ៍ត្រូវមានគុណភាពល្អមានអនាម័យ (មិនចំលងរោគ) ផ្តល់ផលប្រយោជន៍ដល់ដីស្រែ ចំការ មិននាំឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ រុក្ខជាតិ និងគុណភាពដី។

សំណល់ដែលសល់ពីប្រព្រឹត្តកម្មអែនអែរ៉ូបិក (digestate) ក្រៅពីយកទៅធ្វើជាវត្ថុធាតុដើមធ្វើជីកំប៉ុស្តិ៍ គឺអាចប្រើប្រាស់វាជាផលិតផលជីកំប៉ុស្តិ៍សំរាប់វិស័យកសិកម្ម ដោយគោរពតាមគោលការណ៍ណែនាំក្នុងការប្រើប្រាស់។

### ៤.២ លក្ខខណ្ឌផលិតផលជីកំប៉ុស្តិ៍

ជីកំប៉ុស្តិ៍ជាផលិតផលត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ÷

[១] មានជាតិទឹកនៅក្នុងជីកំប៉ុស្តិ៍មិនត្រូវលើសពី ៤៥ភាគរយ និងតំលៃ pH ត្រូវស្ថិតនៅក្នុងតំលៃជុំវិញ ៧។

[២] មានសមាសធាតុលោហៈធ្ងន់នៅក្នុងជីកំប៉ុស្តិ៍ មិនឱ្យលើសកម្រិតអតិបរមាដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ៨ នៃគោលការណ៍ណែនាំនេះ។

[៣] មានសារធាតុសរីរាង្គ និងសារធាតុចិញ្ចឹមផ្សេងៗទៀតនៅក្នុងជីកំប៉ុស្តិ៍ (ដោយមានធ្វើការសាកល្បង និងប្រកាសពីលទ្ធផល) ដើម្បីបង្កើនជីជាតិដី និងផលិតផលដំណាំកសិកម្ម។

[៤] គួររក្សាទុកផលិតផលជីកំប៉ុស្តិ៍ឱ្យបានមួយសប្តាហ៍ក្រោយផលិតរួច មុនយកវាទៅប្រើប្រាស់។

[៥] ត្រូវយកជីកំប៉ុស្តិ៍ទៅធ្វើការពិសោធន៍ជាប្រចាំនៅមន្ទីរពិសោធន៍ដែលមានអាជ្ញាប័ណ្ណ ដើម្បីរក្សាគុណភាព។

[៦] នៅពេលដំណើរការធ្វើជីកំប៉ុស្តិ៍នៅក្នុងរង ឬពំនូកត្រូវមានសីតុណ្ហភាពក្នុងករណី៖

ក) ៥៥អង្សាសេ ក្នុងរយៈពេល ២សប្តាហ៍ ជាប់គ្នា ឬ

ខ) ៦៥អង្សាសេ ក្នុងរយៈពេល ១សប្តាហ៍ ដោយមិនមាន ឬបើមានត្រូវនៅក្នុងករណីទាបបំផុតនូវភាពរអាក់រអួល។

ក្នុងបំណងធ្វើឱ្យជីកំប៉ុស្តិ៍មានអនាម័យ មិនមានគ្រោះថ្នាក់ និងចំលងរោគដល់មនុស្ស សត្វ និងរុក្ខជាតិ។

[៧] មិនត្រូវមានបុសស្មៅ និងគ្រាប់រុក្ខជាតិដែលអាចដុះបាននៅក្នុងផលិតផលជីកំប៉ុស្តិ៍ទេ។ ដើម្បីបំពេញតាមតម្រូវការអនាម័យនេះ ពេលដំណើរការធ្វើជីកំប៉ុស្តិ៍ ត្រូវអនុវត្តតាមការណែនាំនៅចំណុច[៦] ខាងលើ។

[៨] មិនមានសមាសធាតុដូចជា ប្លាស្ទិក កៅស៊ូ លោហៈ កែវ ថ្ម... នៅក្នុងផលិតផលជីកំប៉ុស្តិ៍ ÷

ក) ក្នុងករណីមានវត្ថុមានសមាសធាតុខាងលើ (លើកលែងថ្ម) ទំហំរបស់វាមិនអនុញ្ញាតឱ្យធំជាង ២មីលីម៉ែត្រ និងមិនឱ្យលើស ១,៥ភាគរយ នៃទំងន់សរុបរបស់ជីកំប៉ុស្តិ៍ (គិតជាទំងន់ជីកំប៉ុស្តិ៍ស្ងួត)។

ខ) ចំពោះថ្មវិញ ទំហំរបស់វាមិនអនុញ្ញាតឱ្យធំជាង ៥ មីលីម៉ែត្រនិងមិនលើស ៥ភាគរយ នៃទំងន់សរុបរបស់ជីកំប៉ុស្តិ៍ (គិតជាទំងន់ជីកំប៉ុស្តិ៍ស្ងួត)។

[៩] នៅមានលក្ខខណ្ឌផ្សេងៗទៀត ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ៩ជាអនុសាសន៍។

## ៥. តំរូវការសំរាប់ដំណើរការធ្វើជីកំប៉ុស្តិ៍

ដើម្បីឱ្យដំណើរការធ្វើជីកំប៉ុស្តិ៍ និងផលិតផលចុងក្រោយ (ជីកំប៉ុស្តិ៍) មានអនាម័យ និងបំពេញបាននូវល័ក្ខខ័ណ្ឌបទដ្ឋានដូចបានបញ្ជាក់នៅក្នុងចំណុចខាងលើ មានកត្តាជាច្រើនទៀតដែលទាមទារត្រូវបំពេញ៖

[១] ត្រូវមានបុគ្គលិកគ្រប់គ្រាន់ មានសមត្ថភាព និងមានជំនាញក្នុងការបំពេញការងារ ហើយបុគ្គលិកត្រូវមានមធ្យោបាយការពារសុវត្ថិភាពផ្ទាល់ខ្លួន យ៉ាងហោចណាស់មានស្រោមដៃ ម៉ាសការពារធូលី នៅពេលជ្រោយត្រឡប់និងរែង។

[២] ត្រូវពិនិត្យ និងមានចងក្រងជាឯកសារនូវវត្ថុធាតុដើមដែលដឹកចូល ទាំងបរិមាណ ប្រភេទ និងប្រភព ហើយត្រូវពិនិត្យដោយភ្នែកនូវបរិមាណសំណល់នាំចូលទៅទីលានធ្វើជីកំប៉ុស្តិ៍ ព្រមទាំងត្រូវតាមដាន និងវិភាគសារធាតុពុលដែលមាននៅក្នុងសំណល់ភក់ និងសំណល់សរីរាង្គផ្សេងៗទៀត ទៅតាមប្រភពដែលនាំចូល។

[៣] ត្រូវប្រញាប់យកសំណល់ដែលងាយបំបែកធាតុ (ដូចជាសំណល់អាហារ) ទៅធ្វើជីកំប៉ុស្តិ៍មុន តាមដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយក្លិន។

[៤] ត្រូវវាស់សីតុណ្ហភាព និងកត់ត្រារង ឬពំនូកធ្វើជីកំប៉ុស្តិ៍រៀងរាល់ថ្ងៃ ដើម្បីធានាឱ្យការធ្វើជីកំប៉ុស្តិ៍ប្រព្រឹត្តទៅបានល្អ។ ដើម្បីធានាអនាម័យរង ឬពំនូកនិមួយៗត្រូវរក្សាសីតុណ្ហភាពអោយបាន ៥៥អង្សាសេ រយៈពេលពីរសប្តាហ៍ ឬ ៦៥អង្សាសេក្នុងរយៈពេលមួយសប្តាហ៍។

[៥] រយៈពេលធ្វើជីកំប៉ុស្តិ៍អាស្រ័យទៅលើបំណងការកំណត់នៃភាពទុំនៃកំប៉ុស្តិ៍ ព្រមទាំងគោលដៅនៃការប្រើប្រាស់វា និងការលាយវត្ថុធាតុដើម ព្រមទាំងសំភារៈ និងបច្ចេកទេសប្រើប្រាស់។ តាមធម្មតារយៈពេលធ្វើជីកំប៉ុស្តិ៍ពី ២ខែទៅ ៦ខែ។ ការធ្វើជីកំប៉ុស្តិ៍ ដោយប្រើសំណល់សួនច្បារជាវត្ថុធាតុដើម បើប្រើបច្ចេកទេសសាមញ្ញ គឺត្រូវប្រើរយៈពេលយូរ។ ការយកសំណល់អាហារលាយនឹងសំណល់ភក់ធ្វើជីកំប៉ុស្តិ៍ ហើយផលិតផលជីកំប៉ុស្តិ៍ ជាជីកំប៉ុស្តិ៍ស្រស់ សំរាប់សាកវប្បកម្ម (Horticulture) ដំណើរការធ្វើជីកំប៉ុស្តិ៍បែបនេះមានរយៈពេលខ្លី។

[៦] អាស្រ័យទៅនឹងទីតាំង ប្រភេទវត្ថុធាតុដើម និងសមត្ថភាពទីលាន ប្រសិនបើមានការធ្វើប្រព្រឹត្តកម្មក្លិន ត្រូវគ្រប់គ្រងឱ្យបានត្រឹមត្រូវ (កាត់បន្ថយឱ្យដល់កំរិតនូវការសាយភាយ) ដោយមានប្រព័ន្ធបញ្ចេញខ្យល់ (ប្រព័ន្ធបឺតខ្យល់ និងសំអាតដោយ

ឆ្លងកាត់មានតំរងជីវៈ)។ ទោះជាការធ្វើជីកំប៉ុស្តិ៍តាមប្រព័ន្ធចំហរ (អៃរ៉ូបិក)ក៏ដោយ ក៏ត្រូវមានការគ្រប់គ្រងក្លិនស្អុយ ដោយធ្វើការជ្រោយត្រឡប់ និងត្រូវជ្រើសរើសទីតាំងទៅតាមល័ក្ខខ័ណ្ឌអាកាសធាតុ និងទិសខ្យល់។

[៧] ត្រូវមានសៀវភៅកត់ត្រា ដែលក្នុងនោះត្រូវកត់ ថ្ងៃ ខែ ឆ្នាំ បរិមាណ ប្រភេទសំណល់ដែលដឹកចូល ព្រមទាំងក្រុមហ៊ុនដឹកជញ្ជូន ដូចមានចែងនៅឧបសម្ព័ន្ធ ៦ ជាអនុសាន៍។

## ៦. ទីលានធ្វើជីកំប៉ុស្តិ៍

### ៦.១ ទីតាំងទីលានធ្វើជីកំប៉ុស្តិ៍

[១] ដើម្បីកាត់បន្ថយការរំខានតាមរយៈការសាយភាយក្លិន ធូលី និងសំលេងដល់ប្រជាពលរដ្ឋ ដែលរស់នៅជុំវិញទីតាំងទីលានធ្វើជីកំប៉ុស្តិ៍ ៖

- ត្រូវស្ថិតនៅចំងាយយ៉ាងតិច ៥០០ម៉ែត្រពីលំនៅដ្ឋាន ឬទីកន្លែងដែលជាតំរោងអភិវឌ្ឍន៍ ចំពោះទីលានធ្វើជីកំប៉ុស្តិ៍ដែលមានសមត្ថភាពទទួលវត្ថុធាតុដើមតិចតួច ឧទាហរណ៍តិចជាង ៣០០០ តោនក្នុងមួយឆ្នាំ ហើយវត្ថុធាតុដើមនោះជាសំណល់សួនច្បារ។
- ការធ្វើជីកំប៉ុស្តិ៍ទ្រង់ទ្រាយតូច ដូចជាការធ្វើជីកំប៉ុស្តិ៍តាមផ្ទះ ជាកូនរង ដាក់ក្នុងធុង ឬនៅតាមសួនច្បារតាមផ្ទះ ការហុយធូលីទៅអ្នកជិតខាងក៏ត្រូវជៀសវាង ទីតាំងអាចស្ថិតនៅចំងាយយ៉ាងតិច ២០ម៉ែត្រពីលំនៅដ្ឋាន ដើម្បីជៀសវាងការហុយធូលីទៅលើលំនៅដ្ឋាន ការពារសុខភាពដល់អ្នករស់នៅជិតខាង។

[២] អាចអនុញ្ញាតឱ្យសាងសង់ចំងាយយ៉ាងតិច ៥០០ម៉ែត្រពីប្រភពទឹកស្អាត។ ហើយអាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងតំបន់នោះជាអ្នកកំណត់អាស្រ័យទៅតាមស្ថានភាពភូមិសាស្ត្រ និងធារាសាស្ត្រ។ ទីលានធ្វើជីកំប៉ុស្តិ៍មិនអនុញ្ញាតអោយសាងសង់នៅតំបន់លិចទឹកទេ។

[៣] អនុញ្ញាតឱ្យសាងសង់ទីលានធ្វើជីកំប៉ុស្តិ៍ចំងាយយ៉ាងតិច ៥០០ម៉ែត្រពីកន្លែងកំសាន្ត។

[៤] សាងសង់កន្លែងធ្វើជីកំប៉ុស្តិ៍ត្រូវមាន ផ្លូវអាចធានាឱ្យបានដំណើរការបានគ្រប់រដូវ កន្លែងស្តុក ប្រព័ន្ធប្រមូលទឹកសំអុយ ទឹកកខ្វក់ព្រមទាំងប្រព័ន្ធបង្ហូរចូលទៅក្នុងអាង

ស្តុក ការិយាល័យមួយដែលអាចស្ថិតនៅខាងមុខផ្លូវចូលខាងក្រៅទីលាន ដើម្បីងាយស្រួលត្រួតពិនិត្យក្នុងការទទួលសំណល់។

## ៦.២ ការសាងសង់ទីលានធ្វើជីកំប៉ុស្តិ៍

[១] អ្នកគ្រប់គ្រងត្រូវគិតគូរពីទំហំទីលានដែលត្រូវសាងសង់ ដើម្បីឱ្យមានគុណភាពទៅនឹងបរិមាណសំណល់ជីវៈ (វត្ថុធាតុដើម) ដែលត្រូវដឹកចូលសំរាប់ធ្វើជីកំប៉ុស្តិ៍ជាមធ្យមក្នុងមួយឆ្នាំ។ គិតគូរដូចនេះក្នុងបំណងជៀសវាងការស្តុកទុកសំណល់យូរ នាំឱ្យមានក្លិនមិនល្អ និងកើតទឹកសំអុយជាដើម។ មានតែសំណល់សួនច្បារទេដែលមានភាពស្អុយរលួយតិច ហើយអាចទុកបានយូរ ដើម្បីបន្ថយមាឌរបស់វា។

បរិមាណសំណល់ស្មៅមានការប្រែប្រួលទៅតាមរដូវ ការធ្វើជីកំប៉ុស្តិ៍ត្រូវយកវាទៅលាយជាមួយសំណល់ឈើឱ្យបានត្រឹមត្រូវ ជៀសវាងធ្វើឱ្យវានៅហាប់គ្មានខ្យល់ និងបញ្ចេញក្លិនស្អុយ។

[២] ទីលានធ្វើជីកំប៉ុស្តិ៍ត្រូវមានផ្លូវចេញចូល កន្លែងធ្វើប្រព្រឹត្តកម្ម កន្លែងរែង ឃ្លាំងស្តុក ប្រពន្ធ័ប្រមូលទឹកសំអុយ ហើយមានការិយាល័យគ្រប់គ្រងនៅខាងមុខច្រកចូលទីលាន ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យការដឹកវត្ថុធាតុដើមចូល។ ទីលានត្រូវមានរបងព័ទ្ធជុំវិញជៀសវាងការចេញចូលដោយគ្មានការអនុញ្ញាត។

[៣] ដើម្បីជៀសវាងការជ្រាបទឹកសំអុយទៅប្រភពទឹកក្រោមដី និងធានាបាននូវគុណភាពជីកំប៉ុស្តិ៍មិនឱ្យមានលាយ ថ្ម គ្រួស ខ្សាច់ និងបង្កលក្ខណៈងាយស្រួលគ្រឿងចក្រ និងយានយន្តដឹកជញ្ជូនដំណើរការបានដោយពុំមានឧបសគ្គ ទាំងរដូវវស្សានិងប្រាំង នៅលើទីលានធ្វើជីកំប៉ុស្តិ៍ទាំងមូល ត្រូវបង្ហាប់ឱ្យហាប់ដោយប្រើសំភារៈដែលមានការជ្រាបទឹកតិចបំផុត ហើយរឹង (ដូចជាក្រាលកៅស៊ូថ្ពល់ ឬចាក់បេតុង)។

លើកលែងតែកន្លែងធ្វើជីកំប៉ុស្តិ៍ដែលមានតែសំណល់សួនច្បារជាវត្ថុធាតុដើម ដែលតិចជាង ១០០០តោនក្នុងមួយឆ្នាំ។

[៤] ក្នុងករណីមានការចាក់សាបនៅលើទីលាន ប្រពន្ធ័បង្ហូរទឹកសំអុយនិងទឹកភ្លៀងដែលហូរកាត់រងជីកំប៉ុស្តិ៍ ត្រូវសាងសង់ធ្វើយ៉ាងណាឱ្យវាហូរចូលទៅក្នុងអាងប្រមូលទឹកសំអុយ។ ត្រូវជៀសវាងទឹកសំអុយនិងទឹកភ្លៀងហូរចូលផ្ទាល់ទៅក្នុងដីឬទឹកទន្លេ

បឹងបួរ។ ចំពោះទឹកភ្លៀងដែលហូរឆ្លងកាត់ដំបូលរោង ហើយមិនហូរឆ្លងកាត់សំណល់ អាចបង្ហូរទៅប្រភពទឹកខាងក្រៅ។

[៥] ទឹកសំអុយអាចប្រើប្រាស់ឡើងវិញក្នុងដំណើរការធ្វើជីកំប៉ុស្តិ៍ ឬបញ្ជូនទៅកន្លែងធ្វើប្រព្រឹត្តកម្មទឹកសំអុយ។

[៦] អាងប្រមូលទឹកសំអុយត្រូវសាងសង់តាមលក្ខណៈបច្ចេកទេស ហើយក្រាលបាតកុំអោយទឹកស្អុយជ្រាបចូលទៅក្នុងប្រភពទឹកក្រោមដី ដោយមានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច។ អាងនេះមាននួនាទីសំរាប់ទទួលទឹកសំអុយ និងទឹកភ្លៀងដែលហូរឆ្លងកាត់រោងធ្វើជីកំប៉ុស្តិ៍។

ទំហំអាងប្រមូលទឹកសំអុយត្រូវសាងសង់ឱ្យសមមាត្រទៅនឹងបរិមាណទឹក ដែលមាន (បច្ចេកទេសសាងសង់មាននៅក្នុងឧបសម្ព័ន្ធ ៩)។

[៧] ប្រព័ន្ធបង្ហូរទឹកភ្លៀងដែលហូរឆ្លងកាត់ដំបូលរោង និងទឹកភ្លៀងដែលមិនហូរឆ្លងកាត់សំណល់ និងប្រព័ន្ធបង្ហូរទឹកសំអុយត្រូវរៀបចំដោយឡែកពីគ្នា។

## ៧. ការអនុញ្ញាតសំរាប់ទីលានធ្វើជីកំប៉ុស្តិ៍

ដើម្បីធានាបាននូវសុវត្ថិភាពបរិស្ថាន ទីលានធ្វើជីកំប៉ុស្តិ៍ត្រូវមានលិខិតអនុញ្ញាតពីក្រសួងបរិស្ថាន លើកលែងការធ្វើជីកំប៉ុស្តិ៍តាមផ្ទះ។ ដើម្បីទទួលបានលិខិតអនុញ្ញាតធ្វើជីកំប៉ុស្តិ៍ អ្នកធ្វើជីកំប៉ុស្តិ៍ត្រូវមានព័ត៌មានដូចខាងក្រោមនេះ÷

[១] វត្ថុធាតុដើម (គុណភាព ប្រភព និងបរិមាណ ដោយយោងទៅតាមប្រភេទ និងសមត្ថភាពទីលានជីកំប៉ុស្តិ៍)

[២] បន្ថែមទៅលើតំរូវការទៅលើការសាងសង់ទីលាន ត្រូវបញ្ជាក់អំពី អាងស្តុកទឹកសំអុយ សំភារៈគ្រប់គ្រង ដំណើរការ ឬផែនការគ្រប់គ្រងក្លិន មធ្យោបាយត្រួតពិនិត្យ។

[៣] បច្ចេកទេសក្នុងដំណើរការគ្រប់គ្រង (ដូចជាក្លិន ការយកទឹកសំអុយប្រើប្រាស់ឡើងវិញ និងការជ្រោយគ្រឡប់ ក្នុងករណីទីតាំងនោះមានបញ្ហាក្លិន)។

[៤] ផលិតផលសំរេចត្រូវមានការបកស្រាយឱ្យបានច្បាស់លាស់យោងតាមឧបសម្ព័ន្ធ ៨។ ក្នុងករណីនេះអ្នកផលិតជីកំប៉ុស្តិ៍មិនចាំបាច់ត្រូវការសុំអាជ្ញាប័ណ្ណទីពីរសំរាប់ប្រើប្រាស់ជីកំប៉ុស្តិ៍ទៀតទេ។

## VI. គោលការណ៍ណែនាំ ស្តីពី ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ

### ១. គោលបំណង

[១] គោលការណ៍ណែនាំនេះមានគោលបំណងកំណត់នូវការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ តាមលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាន នូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ។

[២] គោលការណ៍ណែនាំនេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពនៃការបង្កើត ការបញ្ចេញចោល ការទុកដាក់ ការញែកនៅប្រភព ការប្រមូល ការធ្វើប្រព្រឹត្តកម្ម (កែច្នៃ ដុត និងសំលាប់ ឬរំងាប់មេរោគ) ការដឹកជញ្ជូន និងការបោះចោលចុងក្រោយសំណល់វេជ្ជសាស្ត្រគ្រប់ប្រភេទ។

### ២. ប្រភពសំណល់វេជ្ជសាស្ត្រ

[១] មន្ទីរពេទ្យ មន្ទីរពិសោធន៍ មណ្ឌលសុខភាព មន្ទីរពេទ្យព្យាបាល គ្លីនិក បន្ទប់ពិគ្រោះជំងឺ ។ល។

[២] រោងចក្រ_សហគ្រាសផលិតឱសថ ឱសថស្ថាន។

[៣] លំនៅស្ថាន កន្លែងព្យាបាលសត្វ កសិដ្ឋាន...ដូចជាថ្នាំពេទ្យ សំភារៈដែលសេសសល់ពីការព្យាបាល។

### ៣. ប្រភេទសំណល់វេជ្ជសាស្ត្រ

[១] សំណល់វេជ្ជសាស្ត្រចែកចេញជាបីប្រភេទ (ឧបសម្ព័ន ១០)

- **ប្រភេទ ក** : សំណល់រឹងទូទៅមិនគ្រោះថ្នាក់
- **ប្រភេទ ខ** : សំណល់មុតស្រួចចម្លងរោគ និងមិនចម្លងរោគ
- **ប្រភេទ គ** : សំណល់ចម្លងរោគ ដែលនាំឱ្យគ្រោះថ្នាក់ដល់អ្នកជំងឺ ដល់បុគ្គលិកពេទ្យ និងអ្នកផ្សេងទៀត។

[២] **សំណល់ប្រភេទ ក**

សំណល់រឹងទូទៅមិនគ្រោះថ្នាក់ដូចជាសំណល់ផ្ទះបាយ ការិយាល័យ និងបន្ទប់អ្នកជំងឺ ឬបន្ទប់បុគ្គលិកពេទ្យសំរាក។ សំណល់ប្រភេទនេះមិនទាមទារឱ្យមានវិធានការតឹងរឹងក្នុងការគ្រប់គ្រងពេកទេ ព្រោះវាមិនបង្កគ្រោះថ្នាក់ដល់អ្នកជំងឺបុគ្គលិកពេទ្យ ឬអ្នកផ្សេងទៀត

ក្នុងករណីដែលសំណល់ប្រភេទនេះ មិននៅលាយឡំជាមួយនឹងសំណល់គ្រោះថ្នាក់ប្រភេទ ខ ឬ គ (ឧបសម្ព័ន ១០)។

[៣] **សំណល់ប្រភេទ ខ**

ជាសំណល់មុតស្រួចទាំងឡាយណា ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ ដោយមុតធ្វើឱ្យរបួស និងចម្លងរោគដល់អ្នកជំងឺ បុគ្គលិកពេទ្យ ឬអ្នកផ្សេងទៀត (មើលឧបសម្ព័ន្ធ ១០)។

[៤] **សំណល់ប្រភេទ គ**

ជាសំណល់មានលក្ខណៈគ្រោះថ្នាក់ធ្ងន់ធ្ងរ ចម្លងរោគដល់អ្នកជំងឺ បុគ្គលិកពេទ្យ និង សុខភាព សាធារណៈ ដោយផ្ទាល់ ឬប្រយោល។ សំណល់នេះទាមទារឱ្យមានវិធានការម៉ឺងម៉ាត់ក្នុងការការពារ ការឆ្លងរោគក្នុងពេលធ្វើសកម្មភាពញែកនៅប្រភព ប្រមូល ទុកដាក់ ធ្វើប្រព្រឹត្តកម្ម (សំលាប់មេរោគ ដុត កែច្នៃ) ដឹកជញ្ជូន និង ចាក់ចោលចុងក្រោយ (ឧបសម្ព័ន្ធ ១០)។

## ៤. ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ

### ៤.១ ការញែកសំណល់នៅប្រភព

ការញែកសំណល់វេជ្ជសាស្ត្រនៅប្រភព ត្រូវមានការវេចខ្ចប់ ឬទុកដាក់នៅក្នុងថង់ ឬធុងសំរាមបីប្រភេទដូចខាងក្រោម÷

[១] **សំរាប់សំណល់ប្រភេទ ក** : ដោយសារវាជាសំណល់រឹងមិនបង្កគ្រោះថ្នាក់ត្រូវញែកសំណល់ជីវៈ ដោយត្រូវវេចខ្ចប់ក្នុងថង់ ឬដាក់ក្នុងធុងពណ៌បៃតង ហើយសំណល់មិនមែនជីវៈត្រូវវេចខ្ចប់ក្នុងថង់ពណ៌ខ្មៅដោយមានផ្លាកសញ្ញាសំគាល់។ នៅគ្រប់កន្លែងដែលមានសំណល់ប្រភេទនេះ ត្រូវយកទៅទុកដាក់នៅកន្លែងស្តុកបណ្តោះអាសន្ន យ៉ាងហោចក្នុងមួយថ្ងៃឱ្យបានម្តង។

[២] **សំរាប់សំណល់ប្រភេទ ខ** : សំណល់មុតស្រួចត្រូវញែកឱ្យដាច់ពីសំណល់ប្រភេទ ក និង គ ហើយដាក់ក្នុងប្រអប់ ឬធុងសុវត្ថិភាពពណ៌លឿង ដោយមានផ្លាកសញ្ញាសំគាល់។ នៅពេលដែលប្រអប់នេះពេញ ត្រូវយកទៅបញ្ឆេះក្នុងឡដុត ឬទុកនៅកន្លែងស្តុកបណ្តោះអាសន្នដែលមានសុវត្ថិភាព។

[៣] **សំរាប់សំណល់ប្រភេទ គ:** សំណល់ប្រភេទនេះត្រូវញែកដាច់ពីសំណល់ប្រភេទ ក និង ខ ហើយទុកដាក់ក្នុងថង់ ឬធុងពណ៌ក្រហម ដែលធានាសុវត្ថិភាព (ការលេចធ្លាយជ្រាប បំភាយ)។ សំណល់ប្រភេទ គ អាចយកទៅសំលាប់មេរោគ ឬយកទៅដុតកំទេចនៅក្នុងឡ ឬទុកនៅកន្លែងស្តុកបណ្តោះអាសន្ន។ បើគ្មានកន្លែងដុតកំទេចសំណល់ប្រភេទនេះទេ ត្រូវបញ្ជូនទៅកន្លែងធ្វើប្រព្រឹត្តកម្មដែលប្រកបដោយសុវត្ថិភាព។

### ៤.២ ការទុកដាក់បណ្តោះអាសន្នប្រកបដោយសុវត្ថិភាព

សំណល់វេជ្ជសាស្ត្រគ្រប់ប្រភេទត្រូវទុកដាក់នៅកន្លែងបណ្តោះអាសន្នដែលមានសុវត្ថិភាព ដើម្បីការពារសុខភាពបុគ្គលិកពេទ្យ អ្នកជំងឺ និងអ្នកផ្សេងទៀត។

[១] **សំណល់ប្រភេទ ក** ដែលមានសំណល់សរីរាង្គ និងអសរីរាង្គត្រូវដាក់ដោយឡែកពីសំណល់ប្រភេទ ខ និង គ។

[២] **សំណល់ប្រភេទ ខ និង គ**

ចំពោះសំណល់ទាំងពីរប្រភេទនេះយើងត្រូវ៖

ក) ទុកដាក់នៅទីកន្លែងមានសុវត្ថិភាព (មានដំបូល,ជញ្ជាំងព័ទ្ធជុំវិញ និងមានចាក់សោរ)។

ខ) សំភារៈវេចខ្ចប់ត្រូវធានាគុណភាព និងសុវត្ថិភាព (ធុងត្រូវមានគំរបមិនងាយបែកធ្លាយ រហែក ឬបាក់បែក)។

គ) បន្ទប់ ឬកន្លែងទុកដាក់បណ្តោះអាសន្ន ត្រូវខ័ណ្ឌជញ្ជាំងចែកដាច់ពីគ្នារវាងសំណល់ប្រភេទ ខ និង គ។

គ) រយៈពេលទុកដាក់សំណល់ប្រភេទ ខ គឺអាស្រ័យទៅលើបរិមាណសំណល់។

ឃ) ប្រភេទសំណល់ គ មិនត្រូវស្តុកទុកឱ្យលើសពី ៤៨ម៉ោង ហើយត្រូវដាក់នៅកន្លែងត្រជាក់តាមដែលអាចធ្វើទៅបាន។

## ៥. ការត្រួតពិនិត្យជាប្រចាំសំណល់វេជ្ជសាស្ត្រ

### ៥.១ ភារកិច្ចម្ចាស់សំណល់ប្រភេទ ខ និង គ

[១] ត្រូវធ្វើរបាយការណ៍ទៅក្រុមហ៊ុនដឹកជញ្ជូនឱ្យបានច្បាស់លាស់អំពីប្រភេទ និង បរិមាណសំណល់និមួយៗ ដោយប្រើទំរង់បែបបទដែលមានជូនភ្ជាប់ នៅក្នុងឧបសម្ព័ន្ធ ១១។

[២] ដកហូតទុកទំរង់បែបបទដែលចុះហត្ថលេខាជាមួយក្រុមហ៊ុនដឹកជញ្ជូនពីរច្បាប់ដោយមួយច្បាប់រក្សាទុកខ្លួនឯង ហើយមួយច្បាប់ទៀតបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចបញ្ជាក់ថាបានប្រគល់សំណល់ ឬអំពីមធ្យោបាយធ្វើប្រព្រឹត្តកម្ម ឬចាក់ចោលចុងក្រោយ។

## ៥.២ ភារកិច្ចក្រុមហ៊ុនដឹកជញ្ជូន

[១] ធានាគុណភាព និងសុវត្ថិភាពមធ្យោបាយដឹកជញ្ជូន ហើយមានផ្លាកសញ្ញា សំគាល់ភាពគ្រោះថ្នាក់នៅលើមធ្យោបាយដឹកជញ្ជូន។ ត្រូវយកទំរង់បែបដែលធ្វើជាមួយម្ចាស់សំណល់ តាមខ្លួនជានិច្ច នៅពេលដឹកជញ្ជូន និងត្រូវបញ្ជូនមួយច្បាប់ទៅអាជ្ញាធរមានសមត្ថកិច្ច។

[២] កំណត់ពេលវេលាដឹកជញ្ជូនឱ្យបានច្បាស់លាស់។

[៣] ត្រួតពិនិត្យប្រភេទសំណល់មុននឹងទទួលយក។

[៤] ត្រូវមានអាជ្ញាប័នដឹកជញ្ជូនសារធាតុប្រកបដោយគ្រោះថ្នាក់ ពីអាជ្ញាធរទទួលខុសត្រូវ។ ក្រុមហ៊ុនដឹកជញ្ជូនដែលគ្មានអាជ្ញាប័នអនុញ្ញាតឱ្យដឹកជញ្ជូនសំណល់វេជ្ជសាស្ត្រ មិនអនុញ្ញាតអោយដឹកសំណល់ប្រភេទនោះឡើយ។

[៥] ត្រូវឱ្យអ្នកទទួលសំណល់ចុះហត្ថលេខា ហើយក្រុមហ៊ុនដឹកជញ្ជូនត្រូវរក្សាទំរង់បែបបទមួយច្បាប់ទុកជាឯកសារ និងពីរច្បាប់ទៀតប្រគល់ឱ្យទៅអ្នកទទួល។

## ៥.៣ ភារកិច្ចអ្នកទទួល

**អ្នកទទួលត្រូវ៖**

[១] មានមធ្យោបាយធ្វើប្រព្រឹត្តកម្មលើសំណល់វេជ្ជសាស្ត្រ ដើម្បីធ្វើការចាក់ចោលនោះ។

[២] ត្រូវផ្ទៀងផ្ទាត់របាយការណ៍ និងកំណត់ហេតុរវាងម្ចាស់សំណល់ និងក្រុមហ៊ុនដឹកជញ្ជូន។

[៣] ធ្វើរបាយការណ៍តាមពេលកំណត់ទៅអាជ្ញាធរបរិស្ថានខេត្ត-ក្រុង ដោយភ្ជាប់ទំរង់បែបបទក្នុងឧបសម្ព័ន្ធ ១១ទៅជាមួយ។

[៤] ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ជូនអាជ្ញាធរបរិស្ថានខេត្ត ក្រុងក្នុងករណីមានភាពមិនប្រក្រតី។

[៥] ធ្វើការទុកដាក់សំណល់វេជ្ជសាស្ត្រឱ្យបានត្រឹមត្រូវ ដោយយោងតាមចំណុច ៧ ស្តីពីការបោះបង់ចោលចុងក្រោយ។

## ៦. ការធ្វើប្រព្រឹត្តកម្មសំណល់វេជ្ជសាស្ត្រប្រភេទ ខ និង គ

[១] **ការដុត** (incineration) សំណល់ទាំងពីរប្រភេទខាងលើអនុញ្ញាតឱ្យបោះបង់ចោលនៅលើទីលានបទដ្ឋានសមញ្ញ ឬទីលានអនាម័យក្រោយពេលដុតរួច។

[២] **ការសំលាប់មេរោគ** (disinfection) សំណល់វេជ្ជសាស្ត្រដែលអនុញ្ញាតឱ្យយកបោះបង់ចោលនៅទីលានសំរាប់សំណល់ប្រកបដោយគ្រោះថ្នាក់ លុះត្រាតែមានការសំលាប់មេរោគជាមុន។

[៣] **ការរំងាប់មេរោគជាមុន** (sterilization) សំណល់វេជ្ជសាស្ត្រដែលអនុញ្ញាតឱ្យយកមកប្រើប្រាស់វិញ ឬកែច្នៃ លុះត្រាណាមានការធ្វើរំងាប់មេរោគឱ្យបានត្រឹមត្រូវជាមុនសិន។

## ៧. ការបោះបង់ចុងក្រោយនៃសំណល់វេជ្ជសាស្ត្រ

សំណល់វេជ្ជសាស្ត្រត្រូវបោះបង់ចោលនៅទីលាន ដោយអនុលោមទៅតាមប្រភេទរបស់វាដូចមានចែងក្នុងចំណុច [១] ដល់ [៤] ខាងក្រោមនេះ÷

[១] សំណល់ប្រភេទ **ក** ក្រុមហ៊ុនប្រមូល និងដឹកជញ្ជូនសំណល់ទូទៅមិនគ្រោះថ្នាក់ត្រូវប្រគល់ និងចាក់ចោលនៅទីលានបទដ្ឋានសាមញ្ញឬទីលានអនាម័យ។

[២] សំណល់ប្រភេទ **ខ** មុននឹងយកទៅបោះបង់ចោលនៅលើទីលានអនាម័យ លុះត្រាតែមានការធ្វើប្រព្រឹត្តកម្មជាមុន។

[៣] សំណល់ប្រភេទ **គ** ត្រូវធ្វើការសំលាប់មេរោគ (disinfection) មុនពេលយកទៅចាក់ចោលនៅលើទីលានសំណល់ប្រកបដោយគ្រោះថ្នាក់ ដោយអនុលោមទៅតាមលក្ខណៈបច្ចេកទេសទីលាន។

[៤] សំណល់ប្រភេទ **គ** អនុញ្ញាតឱ្យចាក់ចោលនៅលើទីលានអនាម័យ នៅពេលដុតរួចហើយ។

## ៨. ការពង្រឹង និងបង្កើនសមត្ថភាព

[១] ត្រូវរៀបចំធ្វើការបណ្តុះបណ្តាលទូទៅស្តីអំពីការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ ដល់គ្រូពេទ្យ អ្នកគ្រប់គ្រង និងប្រធានគិលានុប្បដ្ឋាក-យិកា។

[២] ត្រូវមានការអប់រំជាប្រចាំ ដល់គិលានុបដ្ឋាក-យិកា បុគ្គលិកមន្ទីរពេទ្យ មណ្ឌលសុខភាព និងអ្នកសំអាត (អនាម័យ) អំពីការញែកសំណល់នៅប្រភព និងការយល់ដឹងទូទៅ។

[៣] ត្រូវផ្តល់ការអប់រំអំពីការញែកសំណល់នៅប្រភព និងបច្ចេកទេសប្រើសំភារៈដល់អ្នកបើកថយន្តពេទ្យ អ្នកធ្វើការតន្លែងធ្វើប្រព្រឹត្តកម្មសំណល់។

[៤] ត្រូវមានការបណ្តុះបណ្តលអំពីការប្រមូល ដឹកជញ្ជូន ដល់អ្នកកើប អ្នកប្រមូល និងអ្នកដឹកជញ្ជូន។

[៥] ត្រូវបណ្តុះបណ្តាលអ្នកគ្រប់គ្រងទីលាន ក្នុងនោះមានម្ចាស់ទីលាន និងបុគ្គលិកទាំងអស់ ស្តីអំពី ដំណើរការទីលាន។

# VII. គោលការណ៍ណែនាំ ស្តីពី ការអប់រំបរិស្ថាន

## ១. គោលបំណង

[១] ធ្វើឱ្យប្រជាពលរដ្ឋ និងសាធារណៈជនគ្រប់ស្រទាប់ជាន់ថ្នាក់បានយល់និងស្គាល់ពីសារៈសំខាន់នៃកិច្ចការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិក្នុងពេលបច្ចុប្បន្នក៏ដូចអនាគត។

[២] ធ្វើឱ្យប្រជាពលរដ្ឋមានមនសិការ និងសមត្ថភាពយល់ដឹងអំពីបរិស្ថានព្រមទាំងចូលរួមការពារបរិស្ថាន តាមរយៈទង្វើ ឬសកម្មភាពរស់នៅរបស់ខ្លួន និងបំរែបំរួលបរិស្ថានក្នុងតំបន់ និងទូទាំងពិភពលោក ហើយនិងមានសមត្ថភាពចូលរួមក្នុងកិច្ចពិភាក្សាស្វែងរកដំណោះស្រាយ អំពីបញ្ហាបរិស្ថាន ដែលកើតមាននៅមូលដ្ឋានរស់នៅរបស់ខ្លួនផងដែរ។

## ២. គោលការណ៍អប់រំបរិស្ថាន

[១] ផ្តល់នូវសញ្ញាណសំខាន់ៗដល់សាធារណជនពីភាពចាំបាច់នៃកិច្ចការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិ។

[២] បង្ហាញឱ្យសាធារណជនយល់ដឹងពីអត្ថប្រយោជន៍នៃបរិស្ថាន ធម្មជាតិ ជាមូលដ្ឋានបង្កើតឱ្យមានបរិស្ថានសង្គម_វប្បធម៌សំរាប់ការអភិវឌ្ឍន៍សមស្របតាមទំនៀមទំលាប់ប្រពៃណី ជំនឿសាសនា និងការតស៊ូរបស់សង្គមមនុស្ស។

[៣] ឱ្យយល់ដឹងពីភាពចាំបាច់នៃការទាញយកផល និងអនុផលពីប្រភពធនធានធម្មជាតិ (ព្រៃភ្នំ រ៉ែ ជីវៈចំរុះ សត្វព្រៃគ្រប់ប្រភេទ ទឹក ដី ខ្យល់) មកប្រើប្រាស់ប្រកបដោយចេរភាពបរិស្ថាន។

[៤] ឆ្លុះបញ្ចាំងឱ្យសាធារណជន ឃើញពីភាពទំនាក់ទំនងគ្នារវាង បរិស្ថានធម្មជាតិ បរិស្ថានសង្គម_វប្បធម៌ និងបរិស្ថានមនុស្ស ព្រមទាំងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

[៥] បង្កលក្ខណៈឱ្យសាធារណជន អាចមើលឃើញពីបញ្ហាបរិស្ថាន ដែលបានកើតមានលើភពផែនដីទាំងមូល នាំឱ្យប៉ះពាល់ដល់ការរស់នៅរបស់មនុស្ស សត្វ និងរុក្ខជាតិ។

[៦] បង្កលក្ខណៈឱ្យមានឱកាសក្នុងការបញ្ចេញមតិ និងរៀបចំអនុវត្តគោលនយោបាយបរិស្ថានប្រកបដោយប្រសិទ្ធភាព។

[៧] បង្ហាញឱ្យឃើញពីហេតុប៉ះពាល់បរិស្ថាន ដែលកើតឡើងតាមរយៈការទាញយកផលពីធនធានធម្មជាតិនៅក្នុងតំបន់ និងនៅលើភពផែនដីមកប្រើប្រាស់សំរាប់ផលិតកម្ម ដោយមិនបានធានានិរន្តរភាពបរិស្ថាន។

[៨] បង្ហាញឱ្យឃើញពីអត្ថប្រយោជន៍នៃការបន្តការអនុវត្តន៍ទំនៀមទំលាប់ពីបុរាណមួយចំនួនដែលផ្សាភ្ជាប់ជាមួយធម្មជាតិ ក្នុងការអភិវឌ្ឍន៍ មិនមានការប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន។

[៩] បង្ហាញឱ្យយើងយល់ និងយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងហេតុប៉ះពាល់បរិស្ថាន។

[១០] សំរាប់គ្រូបង្គោល និងអ្នកអប់រំបរិស្ថានត្រូវមានចំណេះដឹងបរិស្ថានទូលំទូលាយ និងមានចំណេះដឹងគរុកោសល្យ

## ៣. មុខសញ្ញា

[១] ការអប់រំបរិស្ថានចាប់ផ្តើមតាំងពីជាមួយឪពុកម្តាយនៅតាមផ្ទះ មតេយ្យសាលា សាលារៀន សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ឧត្តមសិក្សា វត្តអារាម សាលាពុទ្ធិកៈ សហគមន៍ សង្គមស៊ីវិល ស្ថាប័នអប់រំបរិស្ថាន និងនៅតាមកន្លែងបណ្តុះបណ្តាលផ្សេងៗទៀត។

[២] គ្រូបង្រៀន គ្រូបង្គោល និងអ្នកធ្វើការអប់រំបរិស្ថាន ព្រោះអ្នកទាំងនោះមានតួនាទីជាអ្នកអប់រំបរិស្ថាន។

## ៤. ផែនការអប់រំបរិស្ថាន

នៅក្នុងផែនការអប់រំបរិស្ថាន ត្រូវមានការបញ្ជ្រាបចំណេះដឹង ស្តីពី គោលការណ៍គ្រប់គ្រងសំណល់ ការទប់ស្កាត់និងការបង្កើតសំណល់ ការកាត់បន្ថយបរិមាណសំណល់ ការប្រើប្រាស់ឡើងវិញ ការកែច្នៃ និងការទុកដាក់សំណល់រឹងប្រកបដោយសុវត្ថិភាព ព្រមទាំងការយល់ដឹងអំពីការធ្វើជីកំប៉ុស្តិ៍នៅសហគមន៍ និងនៅតាមផ្ទះ។

## ៤.១ ខ្ទឹមសារអប់រំបរិស្ថាន

ខ្ទឹមសារអប់រំបរិស្ថានត្រូវបញ្ច្រាបទៅក្នុងកម្មវិធីសិក្សានៅ តាមមតេយ្យសាលា សាលាចំណេះដឹងទូទៅ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ វត្តអារាម សាលាពុទ្ធិកៈ ឧត្តមសិក្សា និងស្ថាប័នអប់រំផ្សេងទៀត។

**[១] ការអប់រំបរិស្ថាននៅតាមមតេយ្យសាលា**

ក) អប់រំកុមារឱ្យមានទំលាប់បោះចោលសំណល់ក្នុងធុងសំរាម អប់រំឱ្យស្គាល់ប្រភេទសំណល់ដូចជាស្បោងប្លាស្ទិក ក្រដាស លោហៈ (កំប៉ុង ដែក) ជាដើម ។

ខ) អប់រំកុមារឱ្យមានទំលាប់ធ្វើអនាម័យ នៅមុន និងក្រោយបរិភោគអាហារ ត្រូវចេះលាងដៃ។

គ) អប់រំកុមារឱ្យស្គាល់អំពីប្រភេទសត្វ និងរុក្ខជាតិក្នុងស្រុក និងជីវិតផ្សេងៗនៅលើផែនដី តាមរយៈរូបភាព គំនូរ ខ្សែវីដេអូ ទស្សនៈកិច្ចតាមសួនសត្វ។

**[២] ការអប់រំបរិស្ថាននៅតាមសាលារៀន**

ក) បញ្ច្រាបការអប់រំចំណេះដឹងបរិស្ថានទៅក្នុងមុខវិជ្ជានៃកម្មវិធីសិក្សា។

ខ) ណែនាំឱ្យស្គាល់អំពីសម្បត្តិធនធានធម្មជាតិ។

គ) ណែនាំឱ្យស្គាល់លក្ខណៈសំណល់ ប្រភេទសំណល់ ការទុកដាក់ និងភាពគ្រោះថ្នាក់របស់សំណល់ទៅលើបរិស្ថាន និងល័ក្ខខ័ណ្ឌជីវភាពរស់នៅ។

ឃ) ណែនាំឱ្យមានការយល់ដឹងអំពីការបំពុលបរិស្ថានផ្សេងៗ ដូចជាទឹក ដី ខ្យល់ ការរំខានដោយសំលេង និងរំញ័រ។

ង) ឱ្យស្គាល់ប្រភេទជីវៈចំរុះនៅតាមតំបន់និមួយៗ។

**[៣] សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ**

រៀបចំឱ្យមានវគ្គអប់រំបរិស្ថាន ស្តីអំពី ផលប៉ះពាល់តាមរយៈការអនុវត្តន៍វិជ្ជាជីវៈ និងវិធានការទប់ស្កាត់។

**[៤] សកលវិទ្យាល័យ**

គ្រប់សកលវិទ្យាល័យត្រូវមានកម្មវិធីវិទ្យាសាស្ត្របរិស្ថានសំរាប់និស្សិតគ្រប់មុខវិជ្ជាទាំងអស់។

## ៤.២ ផែនការអប់រំបរិស្ថាន

[១] រៀបចំកម្មវិធីអប់រំការយល់ដឹងអំពីបរិស្ថានជាតួនាទីរបស់ក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា។

[២] ត្រូវពង្រីងចំណេះដឹងផ្នែកបរិស្ថាន ដល់គ្រូបង្គោល និងគ្រូអប់រំ គ្រូបណ្តុះបណ្តាលបរិស្ថានគ្រប់ផ្នែកទាំងអស់។

[៣] ត្រូវចូលរួមធ្វើពិសោធស្រាវជ្រាវពាក់ព័ន្ធទៅនឹងកិច្ចការពារបរិស្ថាននៅតាមសាលាឧត្តមសិក្សាបរិស្ថាន។

[៤] ត្រូវបង្កើតនិងអនុវត្តកម្មវិធីអប់រំបរិស្ថានស្ថាប័នគ្រប់ជាន់ថ្នាក់ទាំងអស់ (ស្ថាប័នរដ្ឋឯកជននិងសង្គមស៊ីវិល) ។

[៥] ជំរុញឱ្យមានការចូលរួមក្នុងការងារអប់រំបរិស្ថានដោយស្ម័គ្រចិត្ត។

[៦] គាំទ្រការអប់រំបរិស្ថាននៅតាមបណ្តាសហគមន៍។

[៧] ត្រូវធ្វើការផ្សព្វផ្សាយច្បាប់ និងបរិធានច្បាប់បរិស្ថានដល់ប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់។

[៨] ត្រូវរៀបចំឱ្យមានការអប់រំចំណេះដឹងបរិស្ថានដល់បុគ្គលិក នៅតាមក្រុមហ៊ុន រោងចក្រ សហគ្រាស និងស្ថាប័នផ្សេងៗទៀត។

[១០] ផ្សព្វផ្សាយការអប់រំបរិស្ថាន ជាតួនាទីសំខាន់របស់គ្រប់បណ្តាញសារព័ត៌មាន និងសង្គមស៊ីវិល ។

## ៤.៣ សកម្មភាពអប់រំបរិស្ថាន

ដើម្បីចូលរួមអនុវត្តឱ្យមានប្រសិទ្ធិភាព ការអប់រំបរិស្ថានត្រូវអនុវត្តក្រោមរូបភាពសំខាន់ៗដូចតទៅ÷

[១] ការបើកវគ្គអប់រំបណ្តុះបណ្តាល

[២] ការរៀបចំសិក្ខាសាលាលើប្រធានបទបរិស្ថាន

[៣] ការបោះពុម្ពផ្សាយ (ឯកសារអប់រំបរិស្ថាន រូបភាពផ្សព្វផ្សាយ ទស្សនាវដ្តី...)

[៤] ការផលិតខ្សែវីដេអូអប់រំបរិស្ថានខ្លីៗ

[៥] ការធ្វើបង្ហាញ។